# ព្រះសូរសៀងរបស់ព្រះ នៅថ្ងៃចុងក្រោយ

ជាការពិតណាស់វាជាឯកសិទ្ធិមួយ ក្នុងការត្រឡប់មកវិញក្នុងចំណោមប្រជាជន អេស្ប៉ាញសារជាថ្មីម្តងទៀតនៅព្រឹកនេះ។ ហើយខ្ញុំឆ្ងល់ថាតើលោកជីមទទួលបានវាយ៉ាងម៉េច។ អូគាត់បានថតសំឡេងនោះទុក។ ខ្ញុំថតសំឡេងបានបន្តិចពីក្រុមចម្រៀងអេស្ប៉ាញបានច្រៀងពេល ដែលខ្ញុំបាននៅទីនោះជាមួយនឹងបងប្រុស កាសាយ។ ហើយខ្ញុំបានភ្លេចពីបទ ចម្រៀងដែល ពួកគេបានច្រៀងឲ្យខ្ញុំស្តាប់។ ប៉ុន្តែ អូ ខ្ញុំចូលចិត្តចម្រៀងនោះណាស់! ហើយកុមារទាំងអស់ គេបានធំធាត់ហើយរៀបការអស់ហើយ។ ខ្ញុំឮពួកគេច្រៀងយូរៗម្តង។ ហើយនៅពេលព្រឹកនេះខ្ញុំបានដើរកាត់ទីនោះហើយក៏ បានឃើញក្មេងប្រុសយ៉ូសែប ហើយឥឡូវនេះវាពិតជាបានធ្វើអ្វីមួយដល់ខ្ញុំហើយខ្ញុំពិតជាសប្បាយចិត្តក្នុងការដែលឃើញគេ។

2 ហើយឥឡូវនេះ ខ្ញុំបានទទួលពាក្យមួយ ដែលខ្ញុំអាចនិយាយបាននៅក្នុងភាសាអេស្ប៉ាញ។ តើអ្នកចង់ឮវាទេ? "ហាលេលូយ៉ា!" ខ្ញុំមិនដែលភ្លេច ពាក្យនោះទេ។ ពេលមួយខ្ញុំបានព្យាយាមយកចិត្តទុកដាក់ដើម្បីទទួលបានការ រំលឹកពីស្រ្តីថ្លង់ម្នាក់។ ឥឡូវនេះអ្នកឃើញទេខ្ញុំអាចនិយាយមិនសូវត្រូវនោះទេប៉ុន្តែពាក្យ ដែលខ្ញុំចាំជាងគេគឺ "អូយេ។" ត្រឹមត្រូវទេ?*ឮ*ខ្ញុំនិយាយទេ។ *ឮទេ* "អូយេ។" ហើយបន្ទាប់មកខ្ញុំមិនដែលភ្លេចមួយពាក្យទេ "**ថ្វាយសិរីរុងរឿងដល់ ព្រះ**!" អស្ចារ្យណាស់! អូ ខ្ញុំមានឱកាសម្តង ខ្ញុំបានទៅរដ្ឋធានីនៃទីក្រុងម៉ិកស៊ិកកូ ហើយខ្ញុំបាននិយាយជាមួយពួក គេនៅទីនោះ។ តើខ្ញុំពិតជាសប្បាយចិត្តយ៉ាងណា! ហើយដែលខ្ញុំធ្លាប់...

3 ខ្ញុំបាននៅប្រទេសហ្វាំងឡង់មុនពេលខ្ញុំបានមកទីនេះ។ ហើយតែងតែ រំលឹកខ្ញុំអំពីការនិយាយជាមួយក្មេងស្រីហ្វាំងឡង់ម្នាក់។ ពួកគេបាននាំខ្ញុំទៅកន្លែងមួយដែលហៅថា "បេថានី"។ គ្រប់ប្រជាជាតិទាំងអស់មានគំនិតរៀងៗខ្លួន។ (តើអ្នកទទួលបានការរំលឹកនេះទេ ខ្ញុំពិតជាមានការចងចាំច្រើនណាស់អ្នកអាចឮថា

តើ វាជាអ្វី?)ក្មេងស្រីតូចម្នាក់នេះនាងគឺជាក្មេងគួរឲ្យស្រឡាញ់។ ប៉ុន្តែ នាងដូច ខ្ញុំ ដែរនាងចូលចិត្តនិយាយច្រើន។ ហើយអ្នកបកប្រែ...នាងនិយាយញាប់ណាស់ ហើយ—ហើយអ្នកបកប្រែមិនអាចនិយាយលឿនដូចដែលនាងនិយាយ នោះទេ។ ហើយនាងក្រោកឡើងនិយាយទាំងមុខរបស់នាងឡើងក្រហម នាងបាន និយាយ ថា"ខ្ញុំបានធ្វើវាសម្រាប់ពួកមនុស្សដែលរស់នៅទីក្រុងបាប៊ីឡូន។"

4 ប៉ុន្តែ តើអ្នកដឹងទេ ខ្ញុំបានកត់សម្គាល់ឃើញថា សត្វស្លាប—សត្វស្លាប ទាំងអស់ច្រៀងជាភាសាអង់គ្លេសសត្វឆ្កែព្រុស ជាភាសាអង់គ្លេសទារកយំជា ភាសាអង់គ្លេស។ ខ្ញុំឆ្ងល់ថាអ្វីដែលជាបញ្ហាមកជាប់ជាមួយយើង។ ប៉ុន្តែយើង រាល់គ្នា គិតថាភាសារបស់យើង—របស់យើងនឹងត្រូវក្លាយជាសហស្សវត្សភាសា ជាការ ពិតណាស់។ ប៉ុន្តែពួកយើងនិងពួកគេដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ ជា ការ ពិតព្រោះយើងមានភាសាស្ថានសួគ៌។

5 យើងមានបងប្រុស រ៉ូវ នៅទីនេះជាមួយយើងនៅព្រឹកនេះ គាត់ជា អ្នកការទូតម្នាក់មកពីទីក្រុងវ៉ាស៊ីនតោន។ ខ្ញុំជឿថាគាត់បានបម្រើការងារ ជាមួយ ប្រធានាធិបតីមិនក្រោមប្រាំឬប្រាំមួយឬប្រាំពីរនាក់នោះទេ។ ហើយអ្នកបានដឹង ពី អារម្មណ៍ដែលខ្ញុំមាន ពេលកំពុងឈរនៅលើវេទិកានេះទេ បុរសដែលអង្គុយ នៅ ពីក្រោយខ្ញុំគាត់នឹងនិយាយ។ ប៉ុន្តែទីបន្ទាល់របស់គាត់ តែងតែជាផ្នែកមួយ ដ៏ល្អ ចំពោះខ្ញុំ ហើយជាពិសេសនៅពេលដែលគាត់...ខ្ញុំជឿថាគាត់គឺជា ពួកលូធឺរៀន ប្រសិនបើខ្ញុំមិនច្រឡំទេ ជាកាតូលិកឬលូធឺរៀន លូធឺរៀន។ ហើយគាត់បាន និយាយថា គាត់បាន...ពីអ្វីមួយអំពីការលូនក្រោម ពេនទីកុស្តនៅក្នុងកិច្ចប្រជុំ មួយហើយគាត់ បានក្រោកឡើង...ទីបំផុតគាត់បានធ្វើតាមវិធីរបស់គាត់ ហើយ នៅពេលដែល គាត់ បានធ្វើនេះព្រះអម្ចាស់បានយាងចុះមកសណ្ឋិតលើគាត់ និងប្រទានពរគាត់ជាច្រើន ...ខ្ញុំគិតថាគាត់អាច និយាយបានប្រហែលប្រាំពីរ ភាសាផ្សេងគ្នា។ ហើយបាន និយាយថាលោកបាន ព្យាយាមក្នុងការនិយាយ មួយភាសា "វាមិនអាចបាន" បន្ទាប់មក គាត់បានព្យាយាមនិយាយមួយ ភាសា ផ្សេងទៀត "គាត់នៅតែមិនអាចបានទៀត។" ហើយខ្ញុំគិតថាគាត់អាច និយាយ ភាសាអេស្ប៉ាញជាមួយអ្នកទាំងអស់គ្នាដូចដែលអ្នកទាំងអស់គ្នាអាចស្តាប់បាន។ ដូច្នេះគាត់—គាត់បាន ព្យាយាមប្រើគ្រប់ទាំងភាសា ហើយតែពួកវានៅតែមិនអាច ទៅរួច។ ហើយ ឃើញទេ ដឹងទេ ព្រះទ្រង់ល្អណាស់ ទ្រង់បានយាងចុះមកស្ថិត

លើគាត់ហើយឲ្យ គាត់អាចប្រើភាសាមួយដែលគាត់មិនធ្លាប់ប្រើពីមុនមក "គាត់អាចធ្វើបាន!" នោះជា ការពិតណាស់។ ខ្ញុំគិតថានោះជាវិធីដែលនឹងមាននៅកន្លែងមួយផ្សេងទៀត។

6 ការចងចាំជាច្រើនដែលខ្ញុំចាំនៅក្នុងចិត្តរបស់ខ្ញុំចំពោះក្រុមជំនុំដែលបាន កើនឡើងតែបន្តិចខ្ញុំជឿវា...អូខ្ញុំភ្លេចថាវានៅកន្លែងណា។ វាគឺនៅទីនេះ នៅកន្លែងមួយដែលនៅជិតផ្លូវតុនតូ។ ហើយខ្ញុំអាចចាំបានហើយ។ ខ្ញុំបានគិតពីពាក្យ "ផ្លូវតុនតូ" ដែលជាកន្លែង ដែលក្រុមជំនុំអេស្បាញធ្លាប់ ប្រើនៅកន្លែងថ្វាយបង្គំ។

7 ខ្ញុំបាននិយាយទៅកាន់គ្រូគង្វាលថា "កន្លែងនេះនឹងក្លាយជា ទីកន្លែងដ៏ធំ សម្រាប់ការរីកផុសផុល" បន្ទប់ជាច្រើននៃព្រះវិហារថ្មីគឺសម្រាប់មនុស្ស ល្អ។ ដូច្នេះ ខ្ញុំគិតថានឹងមានកម្មវិធីការរីផុសផុលនៅថ្ងៃណាមួយ។ សូមអ្នកអធិស្ឋានឲ្យមានការរីកផុសផុលនោះ។ ឥឡូវនេះ ខ្ញុំសង្ឃឹមថាវាគ្រាន់តែជាការ ត្រលប់ម្តងទៀតនៃ ការដែលយើងបានចាកចេញ ទៅក្រុមជំនុំផ្សេង។ ខ្ញុំចាំថាខ្ញុំបានឈរនៅ ក្នុងទីធ្លានេះហើយបានផ្អែក ខ្លួនលើរបងតាមដងផ្លូវនោះហើយព្យាយាមដើម្បីចាកចេញពីទីនោះនៅពេលយប់វា ប្រាកដជាការរំជើបរំជួលមួយដែលខ្ញុំមិនដែលបំភ្លេចបាន។ ហើយខ្ញុំបានធ្វើកំណត់ត្រាមួយ—មួយពីក្មេងស្រីនិងបងប្អូន ជាច្រើនដែលបានបាត់បង់ពួកគាត់បានច្រៀងមួយបទរួមគ្នា។ ហើយពួកគេបានព្យាយាមដើម្បីច្រៀងបទ "គ្រាន់តែជឿតាម" ហើយពួកគេមិនបានបង្ហាញវាចេញទេ អ្នកដឹងទេ។ ពួកគេបាននិយាយថាជំនួសឲ្យ "គ្រាន់តែជឿតាម" ពួកគេបានច្រៀងថា"ជឿលើ យេនៀរ" ឃើញទេ។

8 ហើយខ្ញុំចាំបានថាឪបិកា កូនស្រីរបស់ខ្ញុំ សារ៉ា ហើយគេ មិនទាន់បាននិយាយអ្វីនៅឡើយទេពួកគេបាននិយាយថា "ពុក ការច្រៀង លេងក្នុងកំណត់ត្រាតូចនេះ..."ជំនួសឲ្យការនិយាយជា "ភាសាអេស្ប៉ាញ" ពួកគេមិនអាចនិយាយពាក្យថា "ក្មេងស្រីតូចស្អាត ក្មេងស្រីតូចស្អាតច្រៀងបទ 'គ្រាន់តែជឿតាម។'"

9 ប្រសើរណាស់ខ្ញុំចាំថាពួកគេបានអនុវត្តតាមកិច្ចប្រជុំនេះ។ ការរីកផុសផុលនឹងដំណើរការហើយពួកគេធ្វើតាមកិច្ចប្រជុំទៅកាន់ឆ្នេរភាគខាងលិច។ ហើយខ្ញុំ...វាជារឿងតិចតួចដែលបានដក់នៅក្នុងចិត្តខ្ញុំ នៅពេលដែលយើងបានចាកចេញពីរដ្ឋកាលីហ្វូនញ៉ាបងប្រុស ម៉រ ខ្ញុំនិងបងប្រុសប្រោន បានទៅប្រជុំនៅសភា។ ហើយនៅពេលដែល ខ្ញុំបានដើរតាមអគារនៅពេលយប់នោះមានកុមារជាច្រើន

ឈរនៅទីនោះច្រៀងថា"ទ្រង់បានថែរក្សា អ្នក។" អ្នកបានឮទេ។"តាមរយៈពន្លឺថ្ងៃ ឬស្រមោលលោកបានថែរក្សាអ្នក។" ជាច្រើនដងនៅ ក្នុងសាសន៍បរទេសនានា នៅលើសមរភូមិនៃជម្លោះពិភពលោកដែល កំពុងតែព្យាយាមដើម្បីនាំយកសារ របស់ព្រះគ្រីស្ទមក ខ្ញុំនឹងចងចាំពីក្មេង ប្រុសនិង ក្មេងស្រីទាំងនោះដែលបាន ច្រៀងបទចម្រៀងនោះសម្រាប់ខ្ញុំដែលមានចំណាងជើង ថា "ទ្រង់បានថែរក្សាអ្នក។ តាមរយៈពន្លឺថ្ងៃឬ ស្រមោល ទ្រង់នៅតែរក្សាអ្នក។" ដូច្នេះជាការបំផុសគំនិតដ៏ អស្ចារ្យមួយសម្រាប់ជាជំនួយ។

10 ការជួបជាមួយគ្រូគង្វាលល្អរបស់អ្នក ហើយសប្បាយចិត្តណាស់ ក្នុងការ ដែលឃើញថាក្រុមជំនុំនេះគឺ រស់ឡើងវិញ និងបានទទួលអគារមួយ ដ៏ស្រស់ស្អាត អស្ចារ្យនេះនៅទីនេះ ការកំណត់ទាំងអស់ គឺនឹងមាន ហើយ មានបន្ទប់ចតរថយន្ត ដ៏ធំដែរ។ គ្រាន់តែជាកន្លែងពិតមួយនៅក្នុងការគ្រប់គ្រង នៃព្រះវិញ្ញាណបរិសុទ្ធ ប្រសិន បើយើងគ្រាន់តែទទួលទ្រង់ឲ្យមក ឃើញហើយដឹងថាយើងកំពុងអំពាវនាវ ឲ្យមានការរីកផុសផុលឡើងវិញ។ ខ្ញុំជឿថាទ្រង់នឹងផ្ដល់ឲ្យ។

11 ឥឡូវ យប់នេះយើងនឹងនៅព្រះវិហារ បងប្រុសអោទឡ័រ ឈ្មោះព្រះវិហារព្រះ យេស៊ូវនៅផ្នែកម្ខាង។ ហើយបងប្រុសអោទឡ័រខ្ញុំជឿ...ក្នុងក្រុមជំនុំសាវកផងដែរ។ ខ្ញុំគិតថាគាត់ គ្រាន់តែហៅឈ្មោះ របស់គាត់គឺឈ្មោះរបស់ព្រះយេស៊ូវ។ ខ្ញុំគិតថា គាត់ជាសាវកនៅក្នុងជំនឿ។ ដូច្នេះហើយយើងត្រូវតែទៅទីនោះ នៅយប់នេះ។ ហើយឥឡូវនេះយើងមិន ត្រូវនិយាយថានេះជាក្រុមជំនុំរបស់ពួកអេស្ប៉ាញ "ឥឡូវ មកទីនោះ" ព្រោះអ្នកបាន ស្ថិតនៅក្នុង កាតព្វកិច្ចរបស់អ្នក។ ហើយ បន្ទាប់មកវា នឹងក្លាយទៅជាការជួបជុំដ៏ធំនៃក្រុមអ្នកជំនួញគ្រីស្ទាននឹងត្រូវបានចាប់ផ្ដើម នៅថ្ងៃ ព្រហស្បតិ៍បន្ទាប់ពីកម្មវិធីនេះត្រូវបានបិទនៅក្នុងព្រះវិហារផ្សេងនៅថ្ងៃព្រហស្បតិ៍។ ហើយនៅក្នុងសន្និបាតនេះ ពួកគេនឹងមានអ្នកអធិប្បាយ ផ្ទើមម្នាក់ហើយដូច្នេះ អូរ៉ល្យបឺតនិងបងប្អូនមេតូឌីសខ្លះដែលទើបតែទទួលការសង្គ្រោះ ហើយពួកគេ បានអះអាងថាគាត់ជាវាគ្មិនមានឥទ្ធិពលខ្លាំងណាស់។ ហើយខ្ញុំប្រាកដថាអ្នកនឹង រីករាយជាមួយសន្និបាតនេះ។ ហើយកុមារជំទង់ទាំងនោះ ពួកគេបានទទួលការ ជួបជុំមួយនៅទីនោះសម្រាប់ក្រុមក្មេងជំទង់ផងដែរដូច ដែលប្អូនប្រុសប្រកាស។ កូនរបស់ខ្ញុំនៅទីនោះដែរ ដូច្នេះពួកគេអាចទទួលការស្គាល់គ្នាដែរ។ ដូច្នេះហើយ

ឥឡូវមកនេះ យើងនឹងរីក រាយក្នុងវត្តមានរបស់ទ្រង់។ សូមព្រះអម្ចាស់ប្រទានពរដល់អ្នក។

12 ឥឡូវនេះខ្ញុំចង់បើកក្នុងព្រះគម្ពីរអាននូវព្រះបន្ទូលនៃព្រះពរមួយចំនួន។ ហើយខ្ញុំជ្រើសរើសនៅព្រឹកនេះគឺតែមួយភ្លែតទេ ខ្ញុំមិនចង់ចំណាយពេលយូរពេក អត្ថបទមួយចំនួនក្នុងចំណោមនោះមាននៅព្រះគម្ពីរ សាំយូអែល ហើយផ្សេងទៀតនៅអេសាយ។ ហើយខ្ញុំអានអេសាយមុន។ ហើយខ្ញុំ...

13 តើអ្នកអាចឮទេ ស្តាប់ឮទាំងអស់គ្នាទេ? ហើយប្រដាប់ថតសំឡេងនេះហាក់ដូចជាមានភាពប៉ះពាល់ខ្លាំងណាស់ចំពោះខ្ញុំ ខ្ញុំមិនដឹងថាហេតុអ្វីបានជាដូច្នេះ។ បើ អ្នកឮសូមលើកដៃឡើង។ ល្អ ល្អ។

14 ឥឡូវនេះខ្ញុំគ្រាន់តែស្អកករបន្តិច ជាការពិតណាស់ ដែលវាមកពីការ និយាយច្រើន។ ហើយចាប់តាំងពីខ្ញុំបាននៅទីនេះ ជាមួយបងប្អូនអេស្ប៉ាញនេះហើយប្រហែលដប់ប្រាំមួយឆ្នាំកន្លងទៅតាមខ្ញុំស្មានប្រហែលជាដប់ប្រាំមួយ ឬដប់ប្រាំពីរឆ្នាំកន្លងមកហើយដែរចាប់តាំងពីខ្ញុំអធិប្បាយមក។ ដូច្នេះខ្ញុំមានការអស់កម្លាំងណាស់ខ្ញុំបាននិយាយហើយថាខ្ញុំនៅតែមានការអស់កម្លាំងប៉ុន្តែខ្ញុំនៅតែបន្តដោយព្រះគុណរបស់ព្រះជាម្ចាស់។

15 ឥឡូវចូរយើងត្រឡប់ទៅកាន់គម្ពីរអេសាយ ជំពូក៤០ ហើយនឹង សាំយូអែលខ្សែទី១ ជំពូកទី១ ឬជំពូក៣។ ហើយខណៈពេលដែល យើងកំពុងកាន់ ចំណុចគម្ពីរសម្រាប់ការអានព្រះបន្ទូលនេះ ខ្ញុំសូមឲ្យពួក យើងអោនក្បាលរបស់យើងសម្រាប់អធិស្ឋាន។

16 ព្រះវរបិតានៃយើងនៅថ្ងៃនេះយើងសូមអរព្រះគុណសម្រាប់ឯកសិទ្ធិ ឈរនៅក្នុងទីសក្ការៈគួរឲ្យស្រឡាញ់នេះ អធិស្ឋានដល់ ព្រះអង្គនិងសម្រាប់ ការងាររបស់ទ្រង់។ ហើយនៅពេលនេះយើងដឹងថាអ្នកបម្រើរបស់ទ្រង់បានឈរនៅក្រោយវេទិកានៅទីនេះឬវេទិកាជាច្រើនទៀតនិងជាមួយនឹងជីវិតដែលខិតខំប្រឹងប្រែងដើម្បីសម្រេចការងាររបស់ទ្រង់។

17 ហើយនៅព្រឹក*នេះ* បាននាំមកវិញនូវការចងចាំមួយនៃការរីកផុសផុល ដែលត្រូវបានកំពុងនឹងចាប់ផ្តើមដោយព្រះវិញ្ញាណបរិសុទ្ធដែលបានចុះមក រាងជាពន្លឺដ៏ធំដូចជាបង្គោលភ្លើងមួយហើយទ្រង់បានមានបន្ទូលថា សារទាំងអស់នឹង

បោសសម្អាតផែនដី។ ហើយឥឡូវនេះ គឺជាប្រវត្តិសាស្ត្រ មួយ។ សារជាពន្លឺនេះបានជះ បំភ្លឺតាមរយៈមនុស្សអស្ចារ្យ លោកអូរ៉ល់រ៉ូប៊ឺត លោកថមមីអូសប៊ើនលោក ថមមីហីកនិងអ្នកផ្សេងទៀតជាច្រើន។ ហើយតាមរយៈកិច្ចខិតខំប្រឹងប្រែងដែល យើងបានរួមគ្នាយើងបានឃើញថា សារនេះបានផ្ទុះឆួលឡើងវិញក្នុងគ្រប់ជាតិសាសន៍ទាំងអស់នៅក្រោមមេឃនៃរាជសារពេនតេកុស្ត។ យើងសូមអរព្រះគុណនិងសរសើរតំកើងទ្រង់ ឱព្រះដ៏មានចេស្តា។

18 ហើយឥឡូវនេះយើងអធិស្ឋានហើយត្រៀមចិត្តរបស់យើងជាស្រេច សម្រាប់ការលើកសរសើរដ៏អស្ចារ្យ ដែលនឹងប្រព្រឹត្តទៅក្នុងពេលឆាប់ៗនេះ យើងជឿជាក់។ ហើយប្រសិនបើចិត្តរបស់យើងមិននៅក្នុងស្ថានភាពនេះឬស្ថិតនៅសម្រាប់អ្វីផ្សេងទៀតសូមទ្រង់គង់នៅក្នុងកន្លែងនេះសម្រាប់យើង យើងអធិស្ឋានសូមឲ្យទ្រង់បាន អត់ទោសពីកំហុសរបស់យើង ហើយនឹងមាន ព្រះបន្ទូលទៅពួកយើង នៅថ្ងៃនេះ។ សូមទ្រង់ប្រទានពរដល់គ្រូគង្វាលនៃក្រុមជំនុំនឹងសមាជិកទាំងអស់។ សូមប្រទាន ពរដល់ក្រុមចម្រៀងតូចនេះមានអ្នកលេងព្យ៉ាណូតន្ត្រីនេះផងដែរ។ សូមឲ្យទាំងអស់គ្នាអធិស្ថានដល់ទ្រង់ដែលមានវត្តមាននៅកន្លែងនេះ។ សូមអោយពួកគេបានចេញ ទៅហើយមានការផ្លាស់ប្តូររាល់ពេលជាមួយនឹងទ្រង់នៅពេលពួកគេ បានចូលមក វិញ។ ថ្វាយទាំងអស់ដល់ព្រះវរបិតា។ ហើយថ្វាយពេលវេលាព្រឹកនេះនៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

19 ឥឡូវយើងអាននៅគម្ពីរ អេសាយជំពូកទី៤០វិញ។

*ព្រះនៃឯងរាល់គ្នា ទ្រង់មានព្រះបន្ទូលថា...។ ចូរកំសាន្តទុក្ខ ចូរកំសាន្តទុក្ខរាស្ត្រអញចុះ ត្រូវឲ្យលួងលោមចិត្ត នៃក្រុងយេរូសាឡិមហើយ ស្រែកប្រាប់គេថា គ្រាធ្វើសឹកសង្គ្រាមរបស់គេបានសំរេចហើយ អំពើទុច្ចរិតរបស់គេក៏បានអត់ទោសឲ្យ ហើយគេបានទទួលសំណង១ជា២ពីព្រះហស្តនៃព្រះយេហូវ៉ា ឲ្យស្មងនឹង...អំពើបាបគេដែរ។*

*មានឮព្រះសូរសៀងមួយកំពុងតែស្រែកនៅទីរហោស្ថានថា ចូររៀបចំផ្លូវសំរាប់ទទួលព្រះយេហូវ៉ា ចូរធ្វើឲ្យមានថ្នល់រាបស្មើនៅទីស្ងាត់ថ្វាយព្រះនៃយើងរាល់គ្នាចុះ។*

*ឯគ្រប់ទាំងច្រកភ្នំ នោះនឹងត្រូវលើកឡើង ហើយគ្រប់ទាំងភ្នំធំតូច នឹងត្រូវពង្រាបទៅ នៅកន្លែងណាដែលគ្រលិកគ្រលុក នោះត្រូវធ្វើឲ្យស្មើ ហើយកន្លែងណាដែលរដិបរដុបនឹងត្រូវធ្វើឲ្យរាបចុះ៖*

*នោះសិរីល្អនៃព្រះយេហូវ៉ានឹងសំដែងមក គ្រប់មនុស្សទាំងឡាយនឹងបានឃើញព្រមគ្នា ដ្បិតព្រះឱស្ឋនៃព្រះយេហូវ៉ា បានមានព្រះបន្ទូលហើយ។*

ឥឡូវនៅក្នុងគម្ពីរសាំយូអែលខ្សែទី១ជំពូក៣ខ្ញុំចង់អានខ១-២និងខទី១៩:

*រីឯសាំយូអែល ក្មេងនោះ ក៏ធ្វើការងារថ្វាយព្រះយេហូវ៉ា នៅចំពោះមុខអេលី ក្នុងគ្រានោះ ព្រះបន្ទូលនៃព្រះយេហូវ៉ាកាន់តែក្រទៅ ឯការជាក់ស្តែងក៏មិនសូវមានជាញឹកញយដែរ។*

*នៅគ្រានោះឯងមានពេលមួយដែលអេលីដេកនៅដំណេករបស់លោក សម័យនោះ ភ្នែកលោកបានចាប់តាំងងងឹតទៅ មើលអ្វីមិនឃើញឡើយ*

*...សាំយូអែលក៏ដេកនៅក្នុងព្រះវិហារព្រះយេហូវ៉ាដែរ ជាកន្លែងដែលមានហឹបនៃព្រះក្នុងកាលដែលចង្កៀងនៃព្រះមិនទាន់រលត់នៅឡើយ*

*នោះព្រះយេហូវ៉ាទ្រង់ហៅមក...ហើយសាំយូអែលតបថាប្របាទ។*

ខ19

*សាំយូអែល កាន់តែធំឡើង ហើយ ព្រះយេហូវ៉ាទ្រង់ក៏គង់នៅជាមួយ ហើយមិនឲ្យពាក្យទំនាយណាមួយរបស់លោកជ្រុះធ្លាក់បាត់ឡើយ។*

20 អូ អត្ថបទនេះគ្រប់គ្រាន់ហើយយើងអាចនិយាយបាននៅទីនេះ ក្នុងពេលមួយខែហើយយើងអាចទាញបរិបទ ច្រើនពីអត្ថបទរឿងនេះ។ ប៉ុន្តែនៅព្រឹកនេះយើងមានពេលប្រហែលម្ភៃនាទីដើម្បី ទៅជាមួយគ្នាដ៏ស័ក្តសមរបស់យើង...ខ្ញុំគិតថាថ្នាក់ថ្ងៃអាទិត្យប្រហែលជាចប់ហើយ ឬប្រហែលជាដូចគ្នា ជាមួយយើងដែរ ខ្ញុំដឹងមិនច្បាស់ទេ។ ប៉ុន្តែទោះជាយ៉ាងណា ខ្ញុំចង់ប្រើអត្ថបទនេះគឺ *ព្រះសូរសៀងរបស់ព្រះជាម្ចាស់នៅថ្ងៃចុងក្រោយ។*

21 វាជាពេលវេលាមួយល្អណាស់។ យើងដឹងថាកន្លែងដែលយើង មានក្នុងបទគម្ពីរនេះចែងថា "មិនមានការបើកបង្ហាញនិម្មិតទេ នៅក្នុងសម័យលោកសាំ

យូ អែល។″ ដូច្នេះ ‶កន្លែងដែលមិនមាននិមិត្ត″ បទគម្ពីរចែងថា ‶មនុស្សត្រូវវិនាស។″យើងត្រូវតែមាននិមិត្ត។ ហើយនិមិត្តនោះមកដល់ ពួកហោរាហើយនេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលមានបន្ទូលទៅកាន់ពួកគេ។

22 ហើយយើងបានរកឃើញថាលោកអេលីមិនមែនជាហោរាទេ លោក អេលីជាបូជាចារ្យម្នាក់។ ហើយគាត់ជាចាស់ទុំហើយភ្នែករបស់គាត់ស្រអាប់ ហើយគាត់មិនអាចមើលឃើញអ្វីនៅជុំវិញបានទេគាត់ជាមនុស្សជរាម្នាក់។ ហើយគាត់ចាប់ផ្តើមទុកការងាររបស់ព្រះចោល។

23 ហើយ នោះជាអ្វីមួយដូចទៅនឹងសព្វថ្ងៃនេះ។ ខ្ញុំគិតថាក្រុមជំនុំ ហើយអង្គការ ពួកនិកាយ បានធ្វើព័ន្ធកិច្ចអស់ពេលជាយូរមកហើយ ហើយពួកគេកំពុងតែចាប់ផ្តើមសម្រាក។ ហើយការងារ របស់ព្រះអម្ចាស់ មិនទាន់សម្រេចតាមព្រះបន្ទូលនៃសេចក្តីពិតនោះទេ ព្រោះក្រុមជំនុំនេះបានធ្លាក់ទៅក្នុងសេចក្តីងងឹត។ ហើយយើង ត្រូវការថ្ងៃនេះគឺសំលេងរបស់ព្រះមានបន្ទូលមកពួកយើងដើម្បីនាំយើងត្រលប់ មកដូចដើមវិញ។

24 ហើយ មើលអេលីបានសម្រាក ហើយ...ភ្នែករបស់គាត់បានអន់ថយ។ គាត់គឺជាបូជាចារ្យម្នាក់។ ហើយពួកគេមិនមានការបើកបង្ហាញនិមិត្ត ពីព្រះអម្ចាស់ទេ។ ហើយ នេះជាតម្រូវការដ៏ធំ!

25 ហើយព្រះជាម្ចាស់បានសន្យាថានឹងបំពេញតម្រូវនៅម៉ោងនេះ។ ទ្រង់តែងតែ ធ្វើដូច្នេះ។ ហើយ យើងត្រូវការព្រះសូរសៀងរបស់ព្រះ នៅថ្ងៃនេះ ដើម្បីបំពេញតម្រូវការនៅម៉ោងនេះ ពេលនេះដែលយើងកំពុងតែរស់នៅនោះ។ ហើយបន្ទាប់មកទ្រង់បានសន្យា យើងប្រាកដថាទ្រង់នឹងរក្សាការសន្យារបស់ទ្រង់។ នោះជាទំនុកចិត្តដែលអ្នកជឿមានចំពោះអ្នកបង្កើត ហើយទ្រង់បានសន្យាថានឹងបំពេញគ្រប់ទាំងតម្រូវ។

26 ហើយនៅថ្ងៃនេះហេតុផលមួយ ដែលក្រុមជំនុំនេះស្ថិតនៅ ក្នុងស្ថានភាពមួយនេះ ដោយសារតែមានសំឡេងជាច្រើន បានទាក់ទាញក្រុមជំនុំនេះពីព្រះសូរសៀងរបស់ព្រះជាម្ចាស់រហូតដល់មានការសង្ស័យជាច្រើនថាជាព្រះ សូរសៀងរបស់ព្រះជាម្ចាស់បានមានបន្ទូលមកក្នុងចំណោមពួកគេ។ ពួកគេប្រហែលជាមិនយល់ទេព្រោះជារឿងបរទេសសម្រាប់ពួកគេ។ ពួកគេទទួលសម្លេងដោយខ្លួនឯងជាច្រើនរៀងរាល់ថ្ងៃ!

27 ហើយប្រសិនបើយើងបានកត់សម្គាល់នៅក្នុង បទគម្ពីរដែលយើងបាន អាននេះព្រះសូរសៀងរបស់ព្រះជាភាសារបរទេសសម្រាប់ពួកគេ។

28 ហើយវាបានក្លាយទៅជាដូច្នោះម្តងទៀតនៅថ្ងៃនេះថាជាព្រះសូរសៀងនៃព្រះ...មានសំឡេងជាច្រើនទៀតដូច្នេះដែរ។ ហើយបន្ទាប់ មកប្រសិនបើព្រះបានសន្យាថាទ្រង់នឹងផ្តល់ឲ្យយើងនូវតម្រូវការទាំងនោះហើយសំឡេងផ្សេងទៀតគឺផ្ទុយទៅនឹងព្រះសូរសៀងរបស់ព្រះ បន្ទាប់មកវាត្រូវតែជាសំឡេងសត្រូវរបស់យើងដើម្បីបន្លំយើង នោះយើងមិនអាចយល់ពីព្រះសូរសៀងរបស់ព្រះនៅពេលដែលទ្រង់មានព្រះបន្ទូលឡើយ។

29 ហើយយើងបានកត់សម្គាល់ឃើញថាវា ជាអ្វីដែលស្រដៀងគ្នា រវាងលោកអេលីនិងលោកសាំយូអែលប៉ុន្តែលោកអេលីបានទទួលស្គាល់ថា ផ្លូវដ៏ត្រឹមត្រូវគឺជាព្រះ។ ហើយវាគឺជាការប្រមាថ—ទាំងស្រុងទៅលើលោកអេលី។ ដោយសារតែព្រះសូរសៀងរបស់ព្រះបានមានបន្ទូលទៅលោកសាំយូអែលប្រាប់អំពីការ ធ្វើខុសរបស់លោកអេលីនិងកូនប្រុសរបស់គាត់ហើយពួកគេ បានយកលុយនិង—និងសាច់សត្វពីតង្វាយ។ នោះជាការមិនត្រឹមត្រូវទេ។ នោះហើយជាការដែលពួក គេបានធ្វើខុសផ្ទុយទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។

30 ហើយលោកសាំយូអែលមាន...រឿងតែមួយគត់ដែលលោកអាចធ្វើបាន នឹងនិយាយពិតប្រាកដ។ ហើយគាត់មានការស្ទាក់ស្ទើរបន្តិចក្នុងការធ្វើដូច្នោះព្រោះវាជាការប្រឆាំងនិងកន្លែងដែលគាត់ត្រូវបានបញ្ជូនឲ្យចិញ្ចឹមដោយអេលីនៅ ក្នុងព្រះវិហារ។ ប៉ុន្តែអេលីនិយាយថា "ត្រូវតែនិយាយ។" ឃើញទេ? ហើយគាត់បានប្រាប់ពីរឿងពិត ថាអ្វីដែលនឹងត្រូវកើតឡើង លោកសាំយូអែល...ឬ "ថ្ងៃបញ្ចប់របស់លោកអេលីពីបូជាចារ្យ" ពីព្រោះព្រះបានមានបន្ទូលថា ព្រះទ្រង់បានបញ្ជូនសារ របស់ទ្រង់តាមរយៈ លោកហោរាសាំយូអែល។ កំណើតអស្ចារ្យតាំងពីកុមារ។ ព្រះទ្រង់មានព្រះបន្ទូលទៅគាត់ដូចជាកូនក្មេងហើយបានរៀបចំឲ្យគាត់ធ្វើការងារដែលទ្រង់បានដាក់មក។ ហើយពេលវេលារបស់លោក អេលីត្រូវបញ្ចប់។

31 មានសំឡេងជាច្រើនដូចគ្នានៅ លើផែនដីនៅសព្វថ្ងៃនេះ វាជាការពិតវាជារឿងពិបាកមួយព្រោះ វាជាសំឡេងជំនឿអរូបិយ។ មានសំឡេងជាច្រើនដូចជាសំឡេង លាន់ឮរំពងរបស់ពួកអ្នកខ្លាំងពូកែណាម្នាក់នៅក្នុងចំណោមពួកគេ វាធ្វើឲ្យមានការ វឹកវរក្នុងប្រទេសជាតិ។ ពួកគេមិនមែនជាអ្នករកស៊ីផ្លូវងងឹត ប៉ុន្តែ

ពួកគេបាន អង្រួនប្រជាជាតិហើយនាំយកការអស្ចារ្យរួមគ្នា ធ្វើយុទ្ធនាការយ៉ាងធំនេះ។ ហើយ មនុស្សអាចនឹងមានការយល់ច្រឡំបន្តិច។ វាជាការគ្រប់គ្រាន់ដើម្បីធ្វើឲ្យ គេយល់ច្រលំនៃរបៀបទាំងនេះ។ ហើយព្រះសូរសៀងនិងមានការលើកឡើងដែល—ដែលថានិងធ្វើការទាំងនេះហើយវាបណ្តាលឲ្យសំលេងរបស់ព្រះបានត្រឡប់មកវិញនៅកន្លែងណាមួយដែលជាការពិតនោះគឺជាព្រះសូរសៀងរបស់ព្រះ។

32 "ហើយព្រះសូរសៀងរបស់ព្រះ" ពួកគេនិយាយថា "តើយើងធ្វើដូចម្តេច ដើម្បីដឹងថានោះជាព្រះសូរសៀងរបស់ព្រះជាម្ចាស់មែនឬមិនមែន?" ដោយសារតែថ្ងៃនេះ...នោះមកពីលោកជាហោរាត្រឹមត្រូវម្នាក់។ ឥឡូវនេះ ថ្ងៃនេះយើងដឹងថា តើយើងធ្វើដូចម្តេចដើម្បីដឹងថានោះជា ព្រះសូរសៀងនៃព្រះព្រោះវាជាការ បង្ហាញនៃពាក្យទំនាយ។ *នេះ* គឺជាហោរារបស់ព្រះ។ ហើយព្រះសូរសៀងរបស់ ព្រះជាម្ចាស់បាននាំពួកគេត្រឡប់មកវិញការរស់នៅក្នុងជំនឿអរូបី ជាមួយនឹងការ សម្តែងជំនឿអរូបីរបស់ទ្រង់ដោយព្រះបន្ទូលដ៏ពិត។ បន្ទាប់មកយើងបានដឹងថា នោះជាព្រះសូរសៀងនៃព្រះ។ ដោយសារតែ ការអស្ចារ្យ-...ជាច្រើនទៀតកើតឡើងនៅក្នុងអាណាចក្រផ្សេងទៀតលុបបាត់ស្ទើរតែទាំងអស់។ ប៉ុន្តែចាំថាវានឹងបញ្ចេញពន្លឺនៃទ្រង់នឹង ចេញមក! ទ្រង់នឹងធ្វើវាបាន។

33 ឥឡូវ មានសំលេងមួយនៅថ្ងៃនេះនៅក្នុងពិភពនៃនយោបាយ។ ជាសម្លេងដ៏ខ្លាំង។ ហើយមនុស្សពិតណាស់ សព្វថ្ងៃនេះនៅក្នុងឆាកនយោបាយដ៏ខ្លាំងក្លាពួកគេនឹង...បញ្ចូលគ្នាទាំងអស់ និងអ្វីគ្រប់យ៉ាងនៅព្រះវិហាររបស់ពួកគេ។ ហើយជាច្រើនដងយើងបានដឹងថ្មីៗនេះ សម្លេងនៃនយោបាយឮខ្លាំងជាងព្រះសូរសៀងរបស់ព្រះទៅទៀតនៅក្នុងព្រះវិហារ ឬប្រជាជនអាមេរិកមិនដែលធ្វើនូវអ្វីដែលគេធ្លាប់បានធ្វើនោះទេ។ ឃើញទេ? ពួកគេមិនដែលធ្វើវាទេ។ ប្រសិនបើ មានព្រះសូរសៀងនៃព្រះរស់នៅក្នុងព្រះវិហារនោះពួកគេនឹងមិនធ្វើឲ្យមានកំហុសឡើយ។ ប៉ុន្តែសំឡេងនៃនយោបាយច្រើនខ្លាំងក្លាណាស់ នៅក្នុងផែនដីសព្វថ្ងៃនេះ មានសំឡេងខ្លាំងជាងព្រះសូរសៀងនៃព្រះទៅទៀត រហូតដល់មនុស្សបានលក់ ឈ្មោះជាគ្រីស្ទានរបស់ពួកគេសំរាប់តែ ភាពរីករ នៃប្រជាប្រិយភាពការអប់រំនិងអំណាចនៃនយោបាយផងដែរ។ វាជាការអាម៉ាស់មួយក្នុងការដែលយើងឃើញ។ រឿងធំបំផុតដែលប្រទេសជាតិរបស់យើងបានធ្វើជាអ្វីដែលពួកគេ

បានបង្ករឡើង មនុស្សបានបែរមើលនៅជុំវិញហើយ—ហើយជ្រើសយកអ្វីដែលបានបន្សល់ទុកជាគំរូដល់ប្រទេសដទៃផ្សេងទៀត។ ហើយ—ហើយភ្លៃមូតរ៉ុក (PlymouthRock)និង*មីផ្លាវើ* (Mayflower) និងឲ្យពួកគេមកទីនេះនិង—នឹងបានបង្កើតឡើងសេដ្ឋកិច្ចយ៉ាងខ្លាំងដែលយើងមាន។ នេះគឺជារឿងដែលយើងពិបាកក្នុងការវាយប្រយុទ្ធគ្នាយើងបានដាក់ខ្លួនយើង នៅក្នុងកណ្តាប់ដៃរបស់ខ្លួនយើងដោយសារតែព្រះគម្ពីរបានមានបន្ទូលដូច្នោះ។

34 ហើយប្រព័ន្ធរបស់លោកអេលី: ជាបូជាចារ្យម្នាក់ជួសឲ្យហោរា។ ហោរាគឺជាព្រះបន្ទូល។ លោកបូជាចារ្យគឺជាក្រុមជំនុំ។

35 ហើយ វាទទួលបាននៅកន្លែង មួយរហូតដល់វាចាប់ផ្តើមបាត់បង់ដូច្នេះហើយដំណឹងល្អក្លាយជាបរទេសសម្រាប់មនុស្ស។ ពួកគេមិនទទួលនោះទេ។ បន្ទាប់មកអ្នកអាចនិយាយវាប៉ុន្តែពួកគេនៅតែមិនយល់ ព្រោះពួក គេមិនបានទទួលការបណ្តុះបណ្តាលពីវា។ លោកប៉ុលបាននិយាយថា "ប្រសិនបើត្រែផ្តល់នូវសំលេងមិនច្បាស់តើនរណានឹងដឹងថាត្រូវត្រៀមដើម្បី ធ្វើការច្បាំងគ្នាទៅ?"

36 មនុស្សត្រូវតែបានបណ្តុះបណ្តាលទៅ—ទៅ—ទៅជាមួយសំលេង ក្រុមជំនុំត្រែនៃក្រុមជំនុំ "យើងទទួលបានបន្ថែមទៀតនៅក្នុងថ្នាក់ថ្ងៃ អាទិត្យ របស់យើងច្រើនជាងថ្នាក់របស់ពួកគេដែលទទួលបាន។" នោះមិនមែនជារឿងមួយ ធំដុំទេ។"យើងបានទទួលបន្ថែមទៀតនៅក្នុងនិកាយរបស់យើងច្រើនជាងរបស់ពួកគេដែលទទួលបាន។ យើងជានិកាយធំបំផុតក្នុងចំណោមនិកាយទាំងនោះ។" ឃើញទេនោះហើយជាប្រភេទនៃសំឡេងដែលមនុស្សកំពុងហ្វឹកហាត់ស្តាប់។ នៅតាមផ្លូវដែលពួកគេបានចេញទៅដើម្បីទទួលបាននិងការនាំយកមនុស្សមកវិញ។ រាប់សិបដងមនុស្សរាប់សិបពាន់នាក់នៅក្នុងយុទ្ធនាការនេះបាននាំពួកគេមក។ តើអ្វីដែលពួកគេបានចាប់អារម្មណ៍មក? "យើងមានព្រះវិហារធំបំផុត។ យើងមានក្រុម ជំនុំច្រើនជាងគេបំផុត។ យើងទទួលបានសមាជិកច្រើនបំផុតនៅថ្នាក់ថ្ងៃអាទិត្យ។ យើងមានសមាជិកដែលមាន ឋានៈធំៗជាច្រើននាក់មកព្រះវិហារយើង។" នោះអាចជាការល្អប៉ុន្តែប្រសិនបើព្រះវិហារដូចគ្នា តែមិនបានទទួលការបណ្តុះបណ្តាលដើម្បី ឲ្យស្គាល់សំលេងរបស់ព្រះ ត្រែនៃដំណឹងល្អតើធ្វើល្អមានប្រយោជន៍អ្វី?

37 ហើយនៅពេល ដែលរឿងកើនឡើងដូច ដែលបានកើតឡើងក្នុងរដ្ឋាភិបាលរបស់យើងតើនឹងមានរឿងអ្វីកើតឡើង? ក្រុមជំនុំមិនបានស្គាល់ពី សំលេងត្រែ

ហើយពួកគេមិនដឹងថាត្រូវធ្វើនោះទេ។ ការសន្យាដ៏ធំនៃភាពរីកចំរើន ប្រាជ្ញាដ៏អស្ចារ្យបានចូលមក ហើយពួកគេបានទៅកាន់ការព្យាករព្រះគម្ពីរហើយនាំវាមកដូច្នេះ។ ឃើញទេសម្លេងនយោបាយ! ហើយវាបានបង្ហាញថាវាបដិសេធសំលេងនៃសាសនាឬមិនបានធ្វើនូវអ្វី ដែលពួកគេធ្លាប់បានធ្វើគឺសំលេងនៃដំណឹងល្អ។ ដោយសារតែយើងបានសន្យានូវការជាច្រើន យើងសន្យាឲ្យមានការរីកចំរើនហើយមិនមានការសង្ស័យទ្បើយ ប៉ុន្តែអ្វីដែលយើងនឹងទទួលបាន។

38 ប៉ុន្តែនៅតែមិនមានន័យអ្វីសំរាប់អ្នកជឿទេ។ ត្រលប់ទៅ ក្នុងព្រះ គម្ពីរហេព្រើជំពូកទី១១សូមស្តាប់សាវ័កប៉ុលនិយាយរបៀបនៅថ្ងៃនេះ "នៅកន្លែង ស្បែកចៀមនិងស្បែកពពែគឺជារបស់ទុរគតជនមិនមែនជាកន្លែងមួយដែល អាចចូលទៅក្នុងទីក្រុងបានទេ។"

39 ខ្ញុំកំពុងអានសៀវភៅនៅក្នុងក្រុមប្រឹក្សានីសៀ នៅពេលដែលមានបញ្ហាយ៉ាងធំបានមកដល់នៅទីក្រុងរ៉ូមបីរយឆ្នាំ បន្ទាប់ពីការសុគតរបស់ព្រះគ្រីស្ទនៅក្រុមប្រឹក្សានោះនៅពេលដែលក្រុមជំនុំធំ ឈរលើអ្វីដែលជាការត្រឹមត្រូវហើយពួកគេចង់បានព្រះគម្ពីរ។ ហើយពួករ៉ូម៉ាំងបានផ្លាស់ប្រែនៃការជឿលើក ដំបូងនៃក្រុមជំនុំនៃទីក្រុងរ៉ូមបានបញ្ចូលគោលជំនឿឧទាហរណ៍ ដូចជាយើងមានបុណ្យណូអែល ជាដើម។

40 បុណ្យណូអែល ព្រះគ្រីស្ទមិនបានប្រសូតនៅថ្ងៃទីម្ភៃប្រាំខែធ្នូ ជាងដែល ខ្ញុំដឹង នោះទេ។ ហេតុអ្វី ភ្នំក្នុងស្រុកយូដានេះគឺមានព្រិលធ្លាក់ហើយគាត់...វា ផ្ទុយពីបទទំនាយដែលនៅក្នុងព្រះគម្ពីរ។ ទ្រង់បានប្រសូតនៅនិទាឃរដូវដំណាល នឹងកូន ចៀមទាំងអស់បានកើត។ ហេតុអ្វីបានជាទ្រង់ប្រសូតនៅ ក្នុងក្រោលសត្វជំនួសផ្ទះវិញ?ទ្រង់ជាកូនចៀមមួយ។ ហេតុអ្វីបានជាទ្រង់មិនរត់ទៅកាន់អាសនៈរបស់ទ្រង់ដែលជាកន្លែង ទ្រង់ត្រូវគេឆ្កាងឈើឆ្កាង? ទ្រង់ត្រូវគេបញ្ជូនទៅកាន់លើឈើឆ្កាង។ អ្នកបាននាំចៀមទៅកាន់អ្នកពិឃាត។ ទ្រង់ជាកូនចៀមមួយ។ បន្ទាប់មកទ្រង់បានប្រសូតនៅពេលដែលចៀមបានកើតដែរ។

41 ប៉ុន្តែអ្នកឃើញទេ ដើម្បីធ្វើដូចនោះ បានពួកគេមានខួបកំណើតរបស់ព្រះអាទិត្យនៅលើប្រព័ន្ធព្រះអាទិត្យដែលជាព្រះ —ព្រះអាទិត្យនៅក្នុងថ្ងៃទីម្ភៃ ខែធ្នូនេះដល់ថ្ងៃម្ភៃប្រាំខែធ្នូវាមានការពិបាកនៃកាផ្លាស់ប្តូរនៃព្រះអាទិត្យ។ វា—វា បានប្រែប្រួលតិចតួចជារៀងរាល់ថ្ងៃហើយរយៈពេលពេលថ្ងៃវែងជាងៗៗរហូតដល់កំ

ដៅយូរជាងគេក្នុងខែកក្កដា។ ហើយបន្ទាប់មកនៅខែធ្នូថ្ងៃមានរយៈពេលខ្លីជាង។ ហើយ ពេលវេលាបន្ទាប់មកនៅថ្ងៃទីម្ភៃប្រាំ ចាប់ពីទីម្ភៃដល់ទីម្ភៃប្រាំពួករ៉ូម៉ាំង ប្រែរ ជាប្រារព្ធ ពិធីខួបកំណើត របស់ព្រះអាទិត្យជំនួសវិញ។ ដូច្នេះបន្ទាប់មកជូពីទ័រ(Jupiter) ដែលជាព្រះរបស់ពួករ៉ូម៉ាំងបានបញ្ចូលវាហើយនិយាយថា "យើងនឹងយកព្រះបុត្រារបស់ព្រះជាម្ចាស់និងជាខួបកំណើតរបស់ព្រះ អាទិត្យដាក់រួមគ្នាដើម្បីប្រារព្ធពិធីមួយយ៉ាងអស្ចារ្យ។" នោះជាការផ្ទុយ! ហើយ អូ មានការបញ្ចូលជាច្រើនដែលពួកគេបានដាក់នៅទីនោះ!

42 ហើយបន្ទាប់មកនៅពេលដែលសាវកពិតនៃព្រះដែលចង់នៅជាប់ ជាមួយព្រះបន្ទូលដ៏អស្ចារ្យមានដូចជា លោកប៉ូលីខាប លោកអេរីនីស លោកម៉ាទីនជាដើម ពួកបរិសុទ្ធទាំងឡាយនេះចង់នៅជាប់ជាមួយ សេចក្តី ពិត...ហើយនៅពេលដែលពួកគេបាននាំសារតាមរយៈក្រុមប្រឹក្សានីសៀមួយចំនួននៃ មនុស្សទាំងនោះត្រូវបានបដិសេធរហូតដល់មានហោរា បានចូលមកចេញពីវាលរហោស្ថានហើយគ្មានអ្វីនៅរុំខ្លួននោះទេ មានតែស្បែកចៀមរុំខ្លួន ហើយអង្គុយក្នុងការប្រជុំ នោះ។ ប៉ុន្តែពួកគេស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែប្រជាប្រិយភាពពួកគេអស់រយៈពេលដប់ប្រាំថ្ងៃនៃគោលនយោបាយ បង្ហូរឈាមនិងបដិសេធវា។ បន្ទាប់មកយើងមានមួយពាន់ឆ្នាំនៃសម័យកាលងងឹត ឃើញទេ។

43 ប៉ុន្តែព្រះបានសន្យាថាត្រែនឹងបន្លឺសំលេងម្តងទៀត។ ប្រជាជននឹងស្តាប់ព្រះសូរសៀងពិត នៃព្រះបន្ទូលនេះជានិច្ច ហើយតែងតែពិនិត្យ មើលអ្វី ដែលអ្នកនឹងធ្វើតាមព្រះបន្ទូលនៃព្រះ។

44 សំឡេងនៃនយោបាយ។ ហើយយើងនៅក្នុងប្រទេសអាមេរិកនិង ពិភពលោកទាំងមូលមានសំឡេងយ៉ាងខ្លាំងនាពេលបច្ចុប្បន្ននេះ ហើយនេះជា សំឡេងនៃពួកហូលីវូដ។ វាបានចាប់យកពិភពលោក។ សូមឲ្យនរណា ម្នាក់ចេញមកពីហូលីវូដជាមួយអ្វីមួយដែលអ្នករកឃើញវាបានបង្ហាញទូទាំងប្រទេស។ ឥឡូវនេះយើងបានសង្កេតឃើញថាពួកគេបានកំណត់គំរូសម្រាប់ស្ត្រីយើង នៅលើសម្លៀកបំពាក់របស់ពួកគេនិងម៉ូតសក់របស់ពួកគេ។ ពួកគេកំណត់សម្លៀកបំពាក់ នោះ។

45 ក្រុមជំនុំគួរតែស្គាល់ពីសំលេងនៃត្រែរបស់ព្រះជាម្ចាស់! ប៉ុន្តែមាន ការយល់ច្រឡំជាច្រើនព្រោះអ្នកបានមើលឃើញអ្នកដទៃទៀតធ្វើដូច្នោះ ដែរជាគំរូ។ កុំ

ធ្វើជាគំរូនាំខ្លួនឯងតាមប្រភេទនៃឧទាហរណ៍នោះព្រោះ វាអាចវិនាសបាន។ ស្តាប់តែព្រះសូរសៀងរបស់ព្រះជានិច្ចតើទ្រង់មានបន្ទូលអ្វីពីវា។

46 ហើយបន្ទាប់មកយើងចំណាំថា នៅហូលីវូដពួកគេ បានបង្កើតរឿងផ្សេងៗឡើង។ ហើយអនុញ្ញាតឲ្យខ្ញុំនិយាយនៅនេះបន្តិច មុនពេល ដែលយើងចូលទៅផ្នែកផ្សេងបន្ថែមទៀត។ មានមួយ—មួយគឺ មានរឿងដែលចេញមកមិនយូរប៉ុន្មានថាមានបុរសម្នាក់—ម្នាក់ដែលនៅហូលីវូដ...គ្មានអ្វីទេដែល ប្រឆាំងនឹងមនុស្សទេឥឡូវនេះ គាត់មិនស្លាប់ទេ ព្រះគ្រីស្ទបានសុគតសំរាប់យើង ប៉ុន្តែនោះ គ្រាន់តែជាការបង្ហាញគំរូដល់អ្នក។ ពួកគេ បានបង្កើតរឿងតិចតួចដែលក្មេងបានប្រើដើម្បីហៅគឺ "ហូឡាហប់" ហូឡាហប់ឬអ្វីមួយដូចជាចឹង។ ហើយប្រសិនបើអ្នកធ្លាប់កត់សម្គាល់ឃើញថា ភាពឃោឃៅ និងអ្វីដែលអនុវត្តតាមភាគច្រើនមាននៅក្នុងកុមារតូច។ នោះហើយជាការមិនត្រឹមត្រូវទេ។

47 ឥឡូវនេះពួកហូលីវូដគឺពោរពេញទៅដោយ—ដោយការបាញ់ដាក់គ្នា។ ឥឡូវមាននរណាម្នាក់ដែលដឹងពីប្រវត្តិសាស្រ្តថាពួកគេជាមនុស្សនៅក្នុងការ ប្រជែងគ្នានៃសមាជិកផ្សេង—ផ្សេងគ្នាពួកគេ ប្រព្រឹត្តគឺមិនសមជាប្រជាពលរដ្ឋនោះទេពួកគេបំបែកខ្លួន ពួកគេធ្វើដូចជាក្រុមអាល់កាប៉ុន (AlCapone) និងដូចឌីលីជី(Dillinger)ដែរ។ពួកគេទទួលការលេងរឿងរបស់ពួកហូលីវូដតាម—តាមទូរទស្សន៍ដែលពួកគេបានហៅថា "កាំភ្លើងផ្សេង។" ហើយខ្ញុំបានឮនៅលើម៉ាស៊ីន*ទូរទស្សន៍*នៅថ្ងៃផ្សេងទៀតដែលរួមគ្នាលេងវាArnessឬអ្វីមួយឬArnessឬខ្ញុំភ្លេចឈ្មោះរបស់គាត់ ហើយគាត់ត្រូវធ្វើ...គាត់តំណាងឲ្យម៉េត ឌីឡុនដែលត្រូវជាតម្រួតនៅក្នុង ក្នុងកាន់សាស។ ហើយលោកម៉េត ឌីឡុន គឺដូចជាទន្សាយលឿងមួយ។ គាត់បានបាញ់សម្លាប់មនុស្សម្តែប្រាំបីនាក់ដែលជា ប្រជាជនស្លូតត្រង់ចេញទៅក្រៅ ក្រុងដុឌហ្គរងចាំនៅគុម្ពោតព្រៃ។ ហើយនៅពេលដែលបុរសម្នាក់ បានដើរមកមាននរណាម្នាក់បានហៅគាត់ ហើយប្រាប់គាត់ថាមានមនុស្សអាក្រក់ម្នាក់កំពុងមក ដូច្នេះនៅទីនោះហើយ នៅពេលបុរសនោះមកគាត់បាញ់គេពីក្រោយ។ ឥឡូវនេះយើងឃើញថាគាត់ជា"មនុស្សមាឌធំ" ដែលបានតាមមក។ ហេតុអ្វី វាជា—ការពិតវាជាការលើកតំកើងអំពើបាប។ ប៉ុន្តែកុមារតូចៗនៃប្រទេសរបស់យើងអាចប្រាប់ អ្នកអំពីម៉េត ឌីឡុនជាជាងប្រាប់អ្នកអំពីព្រះយេស៊ូវគ្រីស្ទទៅទៀត។ ហាង—ហាង—ហាងលក់ ហាងដប់សេននិងកន្លែង

លក់សម្លៀកបំពាក់ មានលក់កាំភ្លើង—កាំភ្លើងតូចសម្រាប់ក្មេងលេងជាមួយនឹងម្ជុកតូចៗដែល—ដែលអ្នកអាច ទិញបានគ្រប់ទីកន្លែង។ វាមិនអីទេក្នុងការពាក់វាប៉ុន្តែ ខ្ញុំ—ខ្ញុំគ្រាន់តែប្រាប់អ្នក អ្នកយល់ទេ។ បន្ទាប់មកពួកគេ—ពួកគេ ជាអ្នកពាណិជ្ជកម្មពិភពលោក ពួកគេលក់ដាច់ហើយបានបង្កើតប្រាក់ចំនូលរាប់លានដុល្លារពីវា។

48 យើងមានអ្វីដែលយើងហៅថា "ទិវាផ្លូវផាទ្រីក" យើងមានអ្វី ដែលយើងហៅបុណ្យទាំងនេះថា "បុណ្យសាសនា។" ហើយការផ្សព្វផ្សាយ ពាណិជ្ជកម្មនៅពិភពលោកបានកើនឡើងហើយពួកគេរកប្រាក់បានរាប់ លានដុល្លារ។ "ទិវាមាតា" មានបាច់ផ្កាជាច្រើន។ ហេតុអ្វីបានជា រៀងរាល់ថ្ងៃ យើងគួរតែគោរព ដល់ម្ដាយ។ គាត់នៅកន្លែងណាមួយមានវ័យចំនាស់ចូរមើលថែរក្សាគាត់។ ដែលនឹងមានតម្លៃច្រើនជាង ផ្កាទាំងអស់ដែលអ្នកបានផ្ញើឲ្យគាត់ឬអ្វីផ្សេងទៀត។ អ្នកឃើញទេ ប៉ុន្តែពួកគេបានយកវាមក។ វាជាសំលេងមួយ ហើយ—ហើយ យើងលាយវាបញ្ចូលគ្នា។ ការពិតវាមិនត្រឹមត្រូវទេ។ ប៉ុន្តែតើអ្នកនឹងធ្វើអ្វី? សូមមើល យើង—យើងគ្រាន់តែ...

49 ខ្ញុំកំពុងតែព្យាយាម ដើម្បីទៅចំណុច មួយដើម្បីប្រាប់អ្នកពីអ្វីដែលខ្ញុំ—ខ្ញុំ បានជឿ។ ព្រះសូរសៀងនេះគឺកម្របានឮណាស់ជាព្រះសូរសៀងរបស់ព្រះ។

50 ឥឡូវនេះយើងរកឃើញថាពួកគេបានកំណត់ល្បឿន។ ហើយតើអ្នកធ្លាប់បានកំណត់ចំណាំឬទេ?ក្មេងប្រុសៗរបស់យើងបានក្លាយទៅជា "រីគី" និង "អ៊ែលវីស។"អ្នកបានផ្លាស់ប្ដូរឈ្មោះរបស់គេយ៉ាងរហ័សហៅកាត់ថា "មួយ" ឬ "ពីរ" ឬអ្វីមួយ។ កុំធ្វើ នោះគួរឲ្យរន្ធត់មួយ...អ្នកនិយាយថា "តើអ្វីជាភាពខុសគ្នារវាងអត្ថន័យឈ្មោះទាំងនេះ" ហេតុអ្វីបានប្រាកដថាវាពិតជាមានន័យបញ្ជាក់ពីអ្វីមួយ។ ឈ្មោះរបស់ អ្នកជាលក្ខណៈបង្ហាញពីជីវិតរបស់អ្នក។ "**ឥឡូវនេះបងប្រុសប្រានហាំ** អ្នកជឿទៅលើវិទ្យាសាស្ត្រ។" ទេ ខ្ញុំមិនមែនទេ! ខ្ញុំឈរលើ**ព្រះបន្ទូលរបស់ព្រះអម្ចាស់**! ហេតុអ្វី នៅពេលដែលលោកយ៉ាកុបនៅរស់គាត់រស់នៅ នឹងឈ្មោះរបស់លោកដែលជា—ជាអ្នកបោកបញ្ឆោតដណ្ដើមកន្លែង។ ហើយនៅពេលដែលព្រះបានផ្លាស់ប្ដូរគាត់ទ្រង់បានប្ដូរ ឈ្មោះរបស់គាត់។ ព្រះជាម្ចាស់បានប្ដូរឈ្មោះរបស់សូល ទៅជាលោកប៉ុល លោកស៊ីម៉ូន ទៅជាលោកពេត្រុសវិញ។ ជាការពិតណាស់ វាមានអ្វីមួយ។ ហើយ រីគី និង អ៊ែលវីសនិងឈ្មោះដូចជាឈ្មោះសម័យ

ទំនើបរបស់អាមេរិកដែលបានប្រើសិទ្ធិដាក់ឈ្មោះឲ្យកូនម្នាក់ៗដោយស្វ័យប្រវត្តិ។ អ្នកយល់ពីអ្វីដែលខ្ញុំចង់មាន ន័យទេ?

51 ឥឡូវខ្ញុំសង្ឃឹមថាខ្ញុំមិនធ្វើទេ...ខ្ញុំគួរតែត្រឡប់មកវិញល្អជាង និងមិនបន្តឆ្ងាយទៀតពីចំនុចរបស់យើងនោះទេ (អ្នកយល់ពីន័យខ្ញុំទេ?)អ្នកមិនអាចយល់នោះទេ។ ប៉ុន្តែអ្វីទាំងអស់នេះ មិនត្រូវយល់បានដោយមនុស្សធម្មតាម្នាក់ទេ។ ពួកគេចាប់វាមិនបានទេព្រោះពួកគេបាន ទទួលនិន្នាការមួយ។ នោះគឺពួកគេស្តាប់នូវសំលេងទាំងនោះ។

52 មានសំឡេងមួយនៃទស្សនវិទូ កុម្មុយនិស្ត ការសន្យាអ្វីមួយដែល ពួកគេមិនអាចរក្សាបាន។ ហើយភាគរយដ៏ធំនៃប្រជាជនអាមេរិកត្រូវបានរុំជាប់នៅក្នុងកុម្មុយនិស្ត។ ឥឡូវនេះខ្ញុំធ្លាប់បាននៅជាមួយកុម្មុយនិស្ត តំបន់កុម្មុយនិស្តនៅក្នុងប្រទេសអាល្លឺម៉ង់ ខាងកើតនៃទីក្រុងប៉ែកឡាំង។ ពួកគេ មានផ្ទះធំៗ ដើម្បី បង្ហាញតែផ្នែកខាងក្រៅ។ អ្នកគួរតែដើរនៅខាងក្នុងនៃពួកគេ ពួកគេមិនទាន់បានបញ្ចប់ទេ។ វាជាការមិនពិតនៃសេដ្ឋកិច្ចរបស់ពួកគេដែលកំពុង តែព្យាយាម ដើម្បីជំរុញអ្វីមួយជ្រុលពេក។

53 ហើយនៅក្នុងប្រទេស រុស្ស៊ីជាកន្លែង កំណើតនៃលទ្ធិកុម្មុយនិស្ត...ដែលជាច្រើនឆ្នាំកន្លងមកហើយពេលដែលខ្ញុំគ្រាន់តែ ជាគ្រូអធិប្បាយក្មេងម្នាក់ ខ្ញុំចង់និយាយថាសាមសិបបីឆ្នាំកន្លងមកហើយដែលរបបណាស៊ីស របបហ្វាស៊ីសនិងកុម្មុយនិស្ត ត្រូវបានកើតឡើង ខ្ញុំនិយាយ "ខ្ញុំនិយាយក្នុងព្រះនាមនៃ ព្រះអម្ចាស់! ពួកគេទាំងអស់នឹងកើតឡើងនៅ ក្នុងរបបកុម្មុយនិស្ត។" ប៉ុន្តែ តើអ្នក ធ្លាប់គិតថាព្រះជាម្ចាស់បានចាកចេញពី ពួកយើងប្រសិនបើយើងគ្រាន់តែគិត។ មានតែមួយភាគរយនៃប្រទេសរុស្ស៊ី ដែលជាកុម្មុយនិស្តតែ មួយភាគរយ ប៉ុន្តែពួក គេមានភាគរយខ្លះស្ថិតក្នុងការគ្រប់គ្រង។ មួយភាគរយនៃលទ្ធិកុម្មុយនិស្ត...មួយ ភាគរយនៃប្រទេសរុស្ស៊ីគឺជាកុម្មុយនិស្តប៉ុន្តែពួកគេអាចគ្រប់គ្រងបាន។

54 រឿងដូចគ្នានឹងហូលីវូដមួយដែរប៉ុន្តែពួកគេអាចគ្រប់គ្រងបាន។

55 ប្រហែល មួយភាគបីឬពីរភាគបី នៃចំនួនប្រជាជន របស់ក្រុមជំនុំនៃ ព្រះវិហារអាមេរិក និងសមាជិកក្រុមជំនុំនោះ ពួកគេបានស្ថិតក្រោម ការគ្រប់គ្រង នៅក្នុងនិកាយទាំងនោះ។

56 អ្វី ដែលកុម្មុយនិស្តនៅទីនោះត្រូវការគឺ ជាព្រះសូរសៀងរបស់ព្រះជាម្ចាស់ លេចឡើងក្នុងចំណោមពួកគេហើយវានឹងទៅជាការអាម៉ាស់មួយ។

57 នៅក្នុងប្រទេសហ្វាំងឡង់នៅពេលដែល ក្មេងតូចម្នាក់ដែលគេបាន ជួយសង្គ្រោះពីការស្លាប់នៅថ្ងៃនោះហើយ ពួកគេបាននាំខ្ញុំទៅទីឆ្ងាយបីការ៉េជាកន្លែងដែលសហមិត្តតូចបានរស់ឡើងវិញពីការស្លាប់ទាហានកុម្មុយនីស រុស្ស៊ី កំពុងឈរនៅទីនោះជាមួយកាយវិការគោរពបែបរុស្ស៊ីជាមួយនឹង ទឹកភ្នែកដែលកំពុងហូរនៅលើថ្ពាល់ របស់ពួកគេ។ ពួកគេបាននិយាយថា"យើងនឹងទទួលព្រះដែលអាចសង្គ្រោះមនុស្សពីការស្លាប់។" វាជាការធ្វេសប្រហែស នៃព្រះវិហារកាតូលិកនិងព្រះវិហារលូធើរៀន និងអស់ទាំងនិកាយទាំងនោះ ពួកគេបានយកលុយទាំងអស់និងបង្កើតអង្គភាពហើយមិនផ្តល់អ្វីឲ្យប្រជាជនឡើយ។ ពួកគេរស់ នៅដូចប្រជាជនដ៏ទៃ។ មាន...

58 អ្វីដែលរុស្ស៊ីត្រូវការ គឺជាហោរាម្នាក់ដែលយល់ដឹងអំពីព្រះបន្ទូលព្រះជាម្ចាស់ដែលអាច—អាចបិទមាត់គេបាន។ បន្ទាប់មក៩០ភាគរយនឹងអាចគ្រប់គ្រងបាន។

59 អ្វីដែលអាមេរិកត្រូវការ គឺជាសំលេងនៃហោរារបស់ព្រះ ដែលអាចក្រោកឈរឡើងនិងថ្កោលទោសពួកហូលីវូដនិងការថ្កោលទោសរឿងទាំងនេះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទនិងក្រុមជំនុំព្រះវិញ្ញាណបរិសុទ្ធនឹងគ្រប់គ្រង។
ការយល់ច្រឡំជាច្រើនអ្នកឃើញទេ សំឡេងនៃការប្រឆាំងជាច្រើនដែលកំពុងប្រឆាំងគ្នា។

60 ព្រះវិហារ សំលេងរបស់វានីមួយៗចង់បានតែសមាជិកច្រើន។ បាទីស្ទចង់បានសមាជិកទាំងអស់ហើយមេតូឌីស្ទ ព្រីសប៊ីធើរៀនក៏ចង់ បានទាំងអស់ដែរ។ យើងទាំងអស់គ្នាមានការទាំងនេះ។ ហើយពួកកាតូលិចមើលទៅ ដូចជាចង់បាន ទាំងអស់មក។ នោះជាការពិតព្រះសូរសៀងរបស់ព្រះបានចេញពីព្រះគម្ពីរនេះ។ពួកគេគ្រប់គ្រងតាម។

61 ប៉ុន្តែព្រះដ៏ខ្ពស់បំផុតទ្រង់និងគ្រប់គ្រងនៅគ្រាចុងក្រោយ។ ពួកបរិសុទ្ធនិងគ្រប់គ្រងនៅថ្ងៃណាមួយព្រះគម្ពីរ បានចែងមកដូច្នោះ។ ពូកគេនិងគ្រប់គ្រងទាំងអស់។

62 ដូចមានសំឡេងអាក្រក់ជាច្រើនបែប! បន្ទាប់មកមាន សំឡេងនៃការមិន ពិតពីហោរាទាំងនោះ។ នោះជាសំឡេងមួយគួរឲ្យភ័យខ្លាចបុរសម្នាក់ដែលបាន ហៅខ្លួនឯងថាជាហោរា។ ពិតណាស់ហោរាគឺជាគ្រូអធិប្បាយម្នាក់ដែរ។ ពាក្យ សម័យទំនើបគេហៅថា "ព្យាការី" មានន័យថា "បុរសម្នាក់ដែលអធិប្បាយនៅក្រោម ការបំផុសគំនិតមួយ។" មានបុរសម្នាក់ដែលបានឈរនិងហៅខ្លួនឯងថាជាហោរាម្នាក់ហើយបានបដិសេធព្រះបន្ទូល បដិសេធសេចក្តីពិតរបស់ព្រះជាម្ចាស់។ មានសំឡេងជាច្រើនដូច្នេះ!

63 គ្រាន់តែពីរបីនាទីមុន មានបងប្អូននៅទីនោះ បាននាំខ្ញុំមកកន្លែង ដែលត្រូវចូលមកនៅទីនេះប៉ុន្តែខ្ញុំ...ស្មានគាត់ឆ្ងល់ថាហេតុអ្វីបានជាខ្ញុំដើរលើ ចិញ្ចើមផ្លូវទៅវិញទៅមក។ ប្រសិនបើអ្នកនៅទីនេះ ប្អូនប្រុសខ្ញុំបានស្តាប់អ្វីមួយ គឺមិត្តភក្តិរបស់ —របស់យើងជាជនជាតិស្បែកខ្មៅនោះ។ ពួកគេ បានមកព្រះវិហារនៅទីនេះហើយពួកគេបានហៅវិហារនោះថា "អេលីយ៉ាមហាម័ត" ឬអ្វីមួយ "លោកអេលីយ៉ា មហាម័តវ័យក្មេង។" ការលើកឡើងជាមួយនឹងសំលេងនិងនិយាយថាពួកគេគឺ ជាសំលេងដែល នឹង—នាំសាសន៍ស្បែកខ្មៅចេញពីភាពរឹករ៉ុនេះ។ នោះហើយអ្នកឃើញទេពួកគេ—ពួកគេ—ពួកគេមូស្លីមរបស់ពួកគេនៅទីនេះ គឺជាវិហារអ៊ីស្លាមរបស់ពួកគេ។ ហេតុអ្វីបានជា អ្នកមិនយល់នូវប្រវត្តិ របស់វាដែលបង្ហាញនូវការអាក្រក់ទាំងនោះថាវាជាការខុស!

64 មនុស្សស្បែកខ្មៅ គឺដូចជាមនុស្សស្បែកស ស្បែកពណ៌ត្នោតនិង ប្រជាជនស្បែកលឿងដែរ មិនមែនត្រឡប់—ទៅមហាម័តនិយមទេ តែត្រូវត្រឡប់មកជាព្រះគ្រីស្ទដែលជាគោលការណ៍ ដែលព្រះគម្ពីរបានបង្រៀនវិញ។ មហាម័តនិយមគឺវាប្រឆាំងនឹងព្រះបន្ទូល។ ឥឡូវខ្ញុំមានឯកសិទ្ធិ នៃការនាំមុខនេះមហាម័តរាប់ពាន់នាក់ឲ្យក្លាយជាគ្រីស្ទាននៅទីក្រុងឌូបាននៃអាហ្វ្រិកខាងត្បូង។ វាមិនបានផលិតអ្វីនោះទេប៉ុន្តែចិត្តសាស្ត្រ។ ហើយចិត្តវិទ្យាគឺមិនអីទេដរាបណាចិត្តសាស្ត្រមិនបានបដិសេធព្រះបន្ទូលរបស់ព្រះទេ។ ប៉ុន្តែនៅពេលដែលចិត្តសាស្ត្រ បដិសេធព្រះបន្ទូល ហើយចិត្តវិទ្យាគឺខុស។ វាផ្តល់នូវសំឡេងមិនច្បាស់។ មានអ្វីផ្សេងទៀតនឹងរលាយ ប៉ុន្តែព្រះបន្ទូលព្រះមិនសាបសូន្យទេ ព្រះយេស៊ូវមានបន្ទូលដូច្នោះ "ផ្ទៃមេឃនិងផែនដី នឹង រលាយបាត់ទៅតែព្រះបន្ទូលទ្រង់មិន រលាយទេ។" ដូច្នេះ

អ្នកឃើញទេ យើងត្រូវ តែនៅជាប់ជាមួយនឹងព្រះសូរសៀងនៃព្រះបន្ទូលរបស់ទ្រង់ជានិច្ច។

65 ដូច្នេះរឿងជាច្រើនបានច្រឡំគ្នា! មនុស្សដែលងើបឡើងពួកគេមិនស្គាល់ ព្រះបន្ទូលហើយ ពួកគេបាននិយាយថាប្រហែល វា ស្តាប់មើលទៅសមហេតុសមផលណាស់។ របបកុម្មុយនីស្ត គឺជារឿងសមហេតុផលខ្លាំងណាស់ "មនុស្សគ្រប់គ្នាដូចគ្នា។ គ្មាន មូលធននិយមទៀត ពួកគេ ទាំងអស់គឺកុម្មុយនីស្ត។" តើអ្នកធ្លាប់ឈប់គិតថាការរីកផុសផុលមិនពិតគឺជាកុម្មុយនីស្តឬទេ? ហើយតើវាកើតឡើងជាគំរូនៅកន្លែងណា?...ព្រះយេស៊ូវមានបន្ទូលថា "វិញ្ញាណពីរដែលនៅជាប់យើង វាអាចបញ្ឆោតអ្នកជ្រើសតាំងបើអាចទៅរួច។" ហើយអ្វីៗទាំងអស់អារក្ស មាន វាធ្វើ ឲ្យខុសពីប្រក្រតីពីអ្វីដែលព្រះបានបង្កើត។ អំពើបាបជា—ជាការប្រព្រឹត្តអំពើមិន ត្រឹមត្រូវ។ ការកុហកគឺជាការនិយាយពាក្យមិនពិត។ អំពើផិតក្បត់ជា—ជាអំពើមួយដែលខុសពីក្រឹត្យវិន័យរបស់ព្រះ។ អ្នកដែលគ្មានជំនឿទាំងអស់គឺ ជាអ្នកដែលបំផ្លាញជំនឿ។ អ្នកត្រូវតែបដិសេធ សេចក្តីពិតដើម្បីទទួលយក ការបំផ្លាញវិញ។ អ្នកឃើញទេឲ្យច្បាស់ពីសំឡេងទាំងនេះសាកល្បងពួកវាដោយព្រះបន្ទូលមើល ថា តើវាពិតឬអត់។

66 អូ ធ្វើយ៉ាងណាដើម្បីអាចនិង នៅតែបន្តស្តាប់សំលេងទាំងនេះ នាពេលបច្ចុប្បន្ននេះ ប៉ុន្តែ ពេលវេលារបស់ពួកយើងបានកន្លងផុតទៅហើយ។ ប៉ុន្តែមានសំឡេងជាច្រើន បានជាមនុស្សមិនដឹងពីអ្វីដែលពួកគេត្រូវធ្វើនោះទេ។ ពួកមេតូឌីសទីបំផុតនិងលឺពីអ្នកអធិប្បាយបាប់ទីស្ទនៅទីនោះ ហើយពួកគេបានទៅទីនោះ ហើយពួកគេនឹងស្នាក់នៅទីនោះមួយខណៈពេល បន្ទាប់មកពួកគេចូលទៅក្នុងពួកលូធើរៀន។ ហើយនៅក្នុងពេនតេកុស្តនោះពួកគេមានក្រុមផ្សេងៗគ្នាម្នាក់រត់ទៅ ជាមួយនិងម្នាក់ទៀត ហើយម្នាក់ផ្សេងទៀតរត់ទៅរកម្នាក់ទៀតទៅវិញទៅមកៗ។ វាបង្ហាញថាអ្នកគ្មាន លំនឹងក្នុងចិត្តទេ។ ចូរស្តាប់ព្រះសូរសៀងទ្រង់! នៅទីនេះបានសរសេរនៅលើក្រដាសថាព្រះសូរសៀង ព្រះសូរសៀងនឹងបញ្ជាក់ច្បាស់ប្រសិនបើជាសេចក្តីពិត។

67 ពួកជំនុំនៅលើពិភពលោកមិនដឹងថាត្រូវធ្វើអ្វីនោះទេ ពិភពនយោបាយគឺស្ថិតនៅក្នុងភាពចលាចល។ អ្វីគ្រប់យ៉ាងហាក់ដូចជា ស្ថិតក្នុងភាព ចលាចល។ សមាជិករត់ពីទីនេះទៅទីនោះឬផ្សេងៗទៀត ខ្លះពាក់អាវរងា ខ្លះពាក់អាវកៅស៊ូ។

នៅពេលដែលខ្ញុំ នៅទីក្រុងរ៉ូមពួកគេមានដែកគោល១៩ប្រភេទ ខុសៗគ្នាដែល ដំ ចូលព្រះសព្ក ព្រះយេស៊ូវ ហើយមានតែ៣ទេ ប៉ុន្តែក្នុងកំណត់ត្រារបស់ពួកគេមាន១៩ប្រភេទខុសៗគ្នា។ ឥឡូវនេះ អ្វីដែលជាភាពខុសគ្នាចំពោះដែកគោល? ព្រះគ្រីស្ទមិនបានទុកដែកគោលឲ្យយើងថ្វាយបង្គំទេ ទ្រង់ទុកឲ្យយើងនូវព្រះវិញ្ញាណបរិសុទ្ធ ដោយព្រះបន្ទូលទ្រង់! "ទីសម្គាល់ទាំងនេះត្រូវតាមពួកអ្នកដែលជឿតើពួកគេនឹងទទួលបានដែកគោលដើម?" "ពួកគេនឹងមាន... ទីសំគាល់ទាំងនេះនឹងតាមពួកអ្នកជឿ ពួកគេជាកម្មសិទ្ធរបស់និកាយខ្ញុំបានចាប់ផ្តើមដើរតាម?" គាត់បានចាប់ផ្តើពីចំណុចសូន្យ។ ឃើញទេតើសំឡេងនោះផ្ទុយគ្នាយ៉ាងណា?

68 ប៉ុន្តែ "សញ្ញាទាំងនេះនឹងតាមពួកអ្នកដែលជឿនៅក្នុងឈ្មោះខ្ញុំ ពួកគេនឹងដេញអារក្សចេញ។" នោះជាព្រះបន្ទូល។ "ពួកគេនឹងពោលចេញជាភាសា ថ្មី! យកពស់ចេញវានឹងមិនអាចប៉ះពាល់ដល់ពួកគេទេ។ ប្រសិនបើពួកគេផឹកអ្វីពុល នោះនឹងគ្មានការរំខានដល់ពួកគេឡើយ។ ប្រសិនបើពួកគេដាក់ដៃរបស់ពួកគេលើអ្នកឈឺនោះពួកគេនឹងបានជាសះស្បើយវិញ។" ហើយអ្នកមើលការទាំងនេះហើយ បូកបញ្ចូលបទគម្ពីរទាំងអស់ជាមួយគ្នា។

69 ឥឡូវនេះយើងនៅតែម្នាក់ឯងវាមិនបញ្ជាក់ថាគ្មានអ្វីទាំងអស់ទេ។ មានជាកន្លែងដែលពេនតេកុស្តទទួលបាននៅលើផ្លូវខុស។ តើមិនមែនជាព្រះយេស៊ូវមានបន្ទូលថា "មនុស្សជាច្រើននឹងមកឯខ្ញុំនៅថ្ងៃនោះហើយនិយាយថា 'ព្រះអម្ចាស់អើយតើខ្ញុំមិនបានធ្វើការអស្ចារ្យនៅក្នុងឈ្មោះទ្រង់ទេឬអី? តើខ្ញុំមិនបានទស្សន៍ទាយនៅក្នុងឈ្មោះទ្រង់ទេឬ? តើខ្ញុំ មិនបានធ្វើការទាំងនេះ នៅក្នុងឈ្មោះទ្រង់ទេឬ?'" ព្រះយេស៊ូវមានព្រះបន្ទូលថា"ចាកចេញពីខ្ញុំទៅអ្នកធ្វើការទុច្ចរិត ខ្ញុំមិនដែលស្គាល់អ្នក ទេ។" តើអ្នកឃើញទេ បងប្អូនប្រុសស្រីខ្ញុំអើយ ហេតុអ្វីបានជាខ្ញុំថ្កោលទោសនិងចោទប្រកាន់ជំនាន់នេះ? អ្នកអាចនិយាយភាសាដូចពួកទេវតាអ្នកអាច រាំក្នុងព្រះវិញ្ញាណនៅ ជុំវិញក្រុមជំនុំនេះ តែមិនមានអ្វីដែលត្រូវធ្វើជាមួយវាទេ។

70 ខ្ញុំបានឃើញក្រុមខាងមហាម័តរាំនៅជុំវិញនោះ។ ខ្ញុំបានឮពីគ្រូពេទ្យ... គ្រូពេទ្យ ដ៏អាក្រក់គេបានក្រោកឈរឡើងហើយបកប្រែយ៉ាងច្បាស់ពីអ្វីដែលនឹងកើតឡើង ហើយវានឹងកើតឡើងតាមវិធីនោះ។ ខ្ញុំបានឃើញ ខ្មៅដៃលើកឡើង

សរសេរជាភាសាដែលមិនស្គាល់ និងមានតែម្នាក់គត់ដែលអាចអានវាបាន នោះគឺវិញ្ញាណ អាក្រក់។ អ្នកមិនអាចដាក់គោលដៅអស់កល្បរបស់អ្នក នៅលើអារម្មណ៍សាច់ឈាមនោះទេ។ សាតាំងអាចបន្លំជាអារម្មណ៍ទាំងនោះដែរ។ មិន...វាជាការស្គាល់ព្រះគ្រីស្ទ មានអ្វីមួយដែលបានផ្លាស់ ប្តូរនៅក្នុងជីវិតរបស់អ្នក។ សូមមើលពីជីវិតនិងជាគំរូជាមួយនឹងព្រះបន្ទូលនិងមើលតើអ្នកស្ថិតនៅចំនុចណា។ ទទួលយកកំនប់ដ៏ពិត។

71 ថ្វីបើទាំងអស់នេះជាការបន្លំ សម្លេងក្លែងក្លាយ ហោរាក្លែងក្លាយៗអ្វីផ្សេងទៀតដែល បានកើនឡើង ព្រះយេស៊ូវនៅតែមានបន្ទូលនៅក្នុងរឿងទាំងអស់នេះថា "បើអ្នកណាឮសំឡេងយើងហើយតាមយើង"។ ទ្រង់គឺជាព្រះបន្ទូល។ ចូរស្តាប់បទបញ្ជារបស់ទ្រង់សំរាប់យើង នៅថ្ងៃនេះនៅក្នុងសំលេងទាំងនេះ។ ដែលខ្ញុំបាននិយាយថាវានឹងចំណាយ ពេលច្រើនម៉ោងដើម្បីនាំសំលេងទាំងអស់នេះចេញ។ ហើយវាធ្វើឲ្យមនុស្សមានការយល់ច្រឡំ វាជាភាសារបរទេស។ ហើយបន្ទាប់មកអ្នកទាំងអស់មិនអាចទទួលបានឱកាសជាលើកទីពីរទេ តែអ្នកនឹង ទទួលយកវាឥឡូវនេះ។ អ្នកអាចនឹងមិនទទួល បានឱកាសនៅយប់នេះ។ អ្នកអាចនឹងមិនទទួលបានឱកាសនៅថ្ងៃស្អែកដែរ។ គឺឥឡូវ! "នៅពេលអ្នក ឮសំឡេងខ្ញុំចិត្តរបស់អ្នកមិនរឹងរូសដូចនៅក្នុងថ្ងៃ នៃការជំរុញនោះទេ។ ឥឡូវនេះ គឺជាពេល វេលាមួយដ៏ល្អ។ នេះគឺជាពេលដែលអាចទទួលយកបានបើមាននរណានឹងឮសំឡេងខ្ញុំ។" ដែលបានបង្ហាញថាព្រះ សូរសៀងរបស់ទ្រង់នឹងនៅតែមាននៅ កណ្តាលភាពរីករនេះ។ គាត់នៅតែទទួលបានព្រះសូរសៀងមួយ!ហេតុអ្វី? ព្រះសូរសៀងរបស់ទ្រង់នឹងនៅរហូត។ "ផ្ទៃមេឃផែនដីនឹងរលាយបាត់ទៅតែព្រះសូរសៀង របស់ទ្រង់នឹងមិនរលាយបាត់ទេ" ព្រះបន្ទូលទ្រង់។

72 សូមនិយាយម្តងទៀត ក្នុងរយៈពេលប្រាំនាទី យ៉ាងឆាប់រហ័សនេះ។ តើអ្នកចំណាយពេលយូរបន្តិចបានឬទេ? ឥឡូវនេះខ្ញុំប្រញាប់បន្តិច។ តោះយើង គ្រាន់តែមាននរណាម្នាក់ដែលបានឮព្រះសូរសៀងហើយស្តាប់តាម។ របៀបដែលវា បានធ្វើឲ្យពួកគេមានសកម្មភាពអ្វីដែលនាំឲ្យគេចង់ធ្វើ។ ឥឡូវនេះខ្ញុំនឹងរំលង បទ—បទគម្ពីរជាច្រើននៅទីនេះ ដើម្បីតម្រង់ទៅកាន់អ្នកពីរបៀប ដែលវាបានផ្លាស់ប្តូរ ជីវិតរបស់ពួកគេនិងការដែលពួកគេ ទាំងអស់នោះបានក្លាយជា មនុស្សចំឡែកយើងហៅថា "មនុស្សចម្លែក។" មនុស្សគ្រប់រូបដែលធ្លាប់ ជឿថាព្រះជាម្ចាស់ជា

មនុស្សចំឡែក។ ពីព្រោះ ប្រសិនបើអ្នកស្ថិតនៅក្នុងនិន្នាការលោកិយនោះមាន អ្វី ខុសនៅក្នុងអ្នក។ ធ្វើជាគ្រីស្ទានម្នាក់ អ្នកត្រូវក្លាយជា មនុស្សចំឡែកម្នាក់។ "សម្រាប់ការទាំងអស់ដែលអ្នករស់ក្នុងព្រះគ្រីស្ទយេស៊ូវអ្នក ត្រូវទទួលរងការធ្វើទុក្ខ បុកម្នេញពីលោកិយ។ ទ្រង់បានគង់ក្នុងព្រះបន្ទូល ហើយព្រះបន្ទូលបានកើតមក ដោយសារទ្រង់ ប៉ុន្តែលោកិយ មិនបានស្គាល់ទ្រង់ទេ។" ឥឡូវនេះចូរស្តាប់ឲ្យបាន ជិតស្និទ្ធជាងមុន។

73 អ័ដាំបានឮព្រះសូរសៀងរបស់ទ្រង់ នៅល្ងាចដ៏ត្រជាក់ និងបានប្រកបជាមួយ ទ្រង់។ ទីនោះគ្មានការផ្តន្ទាទោសដល់អ័ដាំទេ។ គាត់បានឮព្រះសូរសៀង នៃ ព្រះជាម្ចាស់ហើយគាត់បាននិយាយថា "បពិត្រ ព្រះវរបិតា ឥឡូវនេះ ទ្រង់បានធ្វើឲ្យ ទូលបង្គំដេកលក់។" ហើយអេវ៉ានៅលើដៃរបស់គាត់ សត្វតោ សត្វខ្លា និងសត្វព្រៃ នៅជុំវិញគាត់ គ្មានការអាក្រក់ គ្មានការឈឺ គ្មានការចង់ដឹង ប្រសិនបើគាត់ក្រោក នៅពេលព្រឹក នោះពួកគេនឹងភ្ញាក់ពីព្រឹកព្រលឹមដែរ។ អ័ដាំបានឮព្រះសូរសៀង របស់ទ្រង់នៅក្នុងការដែលគាត់គួរតែបានឮ។

74 ប៉ុន្តែនៅថ្ងៃមួយគាត់ បានឮសំលេងប្រពន្ធរបស់គាត់។ ខ្ញុំគួរតែទុកវាចោល បន្តិចសិនប្រសើរជាង។ ប៉ុន្តែលោកបានស្តាប់សំឡេងខុសវាគឺជាសំឡេង ភរិយា របស់លោក ដែលជាអ្នកដែលជិតស្និទ្ធ បំផុតរបស់គាត់មាននៅលើផែនដីនេះ។ ហេតុអ្វីបានជាគាត់ធ្វើមិនបានដូចលោកយ៉ូប "អ្នកនិយាយដូចជាស្ត្រីល្ងង់ម្នាក់?" ហើយប្រសិនជាអាច ជាតិសាសន៍ទាំងមូលអាចរស់នៅជំនួសឲ្យការស្លាប់វិញ។ វាបានផ្លាស់ប្តូរការពិតរវាងមនុស្សនិងពេលវេលា។ ប៉ុន្តែ គាត់បាន ឮព្រះសូរសៀង ព្រះនៅជាប់នឹងព្រះសូរសៀងនោះ ប៉ុន្តែគាត់បាន ប្រែក្លាយ...តើគាត់អាចដឹងថា ប្រពន្ធរបស់គាត់ខុសយ៉ាងណា? សូមចងចាំថាវាគឺជាការរីករាយ។

75 យើងគិតថាថ្ងៃនេះ អង្គភាពព្រះវិហាររបស់យើង យើងគិតថាវាមានភាព រុងរឿងនាពេលបច្ចុប្បន្ននេះ គឺដោយសារព្រះបានញញឹម មកយើង។ វាមើលទៅ ល្អណាស់។ វាមើលទៅល្អណាស់ នៅពេលដែលមីកាឈរនៅទីនោះពីមុខពួក ហោរាបួនរយនាក់និងអ្នកស្រុកទាំងអស់ជាសមាជិករបស់ពួកគេ ហើយពួកភីលី ស្ទីនគឺនៅទីនោះដែរឬជនជាតិ អាស៊ើរដែរ វាមើលទៅរីកចម្រើនល្អណាស់។ ហោរា ទាំងនេះត្រូវបានប្រាប់ថា "ចូរទៅនៅកន្លែងណា ដែលជាកម្មសិទ្ធិរបស់យើង។ ចូរ ចាប់យកវា!" ប៉ុន្តែ វាមិនមែនជាសំលេងរបស់ ព្រះទេ។ ហើយមីកាបានដាក់បណ្តា

សារសំឡេងទាំងនោះ។ ហើយតើ គាត់បានដឹងបានយ៉ាងដូចម្ដេច? ដោយសារតែនិម្មិតរបស់គាត់គឺជាការពិត ត្រឹមត្រូវដោយព្រះបន្ទូល។ នោះជាវិធីមួយដើម្បីជឿទុកចិត្តហើយឃើញនៅថ្ងៃនេះ វាត្រូវតែជាព្រះបន្ទូលរបស់ព្រះ។

76 បន្ទាប់មកតើអ្នកសម្គាល់ឃើញទេ? បន្ទាប់ពីអ័ដាំបាន ស្ដាប់តាមសំលេងផ្សេងទៀតក្រៅពីព្រះសូរសៀងរបស់ព្រះ ប្រពន្ធរបស់គាត់ ផ្ទាល់...ហើយក្រុមជំនុំបានស្ដាប់សំលេងនៃក្រុមជំនុំរបស់ខ្លួនការចាក់ចូលទៅ ក្នុងគោលជំនឿជំនួស ឲ្យព្រះបន្ទូល ពួកគេបានអនុញ្ញាតឲ្យជីវិតរបស់ពួកគេ រស់នៅក្នុងការដែលពួកគេចង់ធ្វើ។ ដូចដែលពួកគេបានទៅព្រះវិហារនិងជា សមាជិក នៃក្រុមជំនុំមួយយ៉ាងពិតប្រាកដ ទាំងអស់នោះហើយជាបញ្ហា។ ការតភ្ជាប់ ជិតបំផុតដែលអ្នកជឿមាននៅលើផែនដីសម្រាប់ពួកគេគឺព្រះវិហារ។ ប៉ុន្តែពួកអ្នកជឿ អ្នកដែលមានជំនឿពិតប្រាកដ គឺមានការ ជិតស្និទ្ធបំផុតជាមួយព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះបន្ទូលរបស់ព្រះ។

77 ដូច្នេះអ្នកដឹងទេថា អ័ដាំបានដឹងថា គាត់ស្ថិតក្នុងស្ថានភាពយ៉ាងណា ហើយគាត់បានឮព្រះសូរសៀងរបស់ព្រះហៅគាត់ជាថ្មីម្ដងទៀត ហើយគាត់នៅក្នុងស្លឹកល្វា។ ប៉ុន្តែវាគឺជាព្រះសូរសៀងនៃការថ្កោលទោសដល់អ័ដាំថា "ហេតុអ្វីបានជាអ្នកធ្វើដូច្នេះ?"

78 ខ្ញុំឆ្ងល់ថាបើពួកអាមេរិកថ្ងៃនេះ ឬក្នុងពិភពលោកលមានចលាចលសាសនាកើតឡើង ហើយអាមេរិកនឹងក្លាយជា ក្លាយជាជាតិសាសន៍នៃសាសនាមួយនៅពេលឆាប់ៗនេះ។[កន្លែងទទេនៅលើកាសែត—Ed។]

79 តើនរណាបានកំណត់ពេលនោះមុនខ្ញុំ? ខ្ញុំដឹងថាវាជាការថតសំឡេង មួយហើយវានឹងឮពាសពេញពិភពលោកនេះ។ យើងមានកម្មវិធីថតសំឡេង ជាច្រើនដែលគ្រប់សារទាំងអស់ត្រូវផ្សាយនៅលើពិភពលោក និង នៅក្នុងបណ្ដារប្រទេសផ្សេងទៀតៗ។

80 មែនហើយឥឡូវនេះ ប្រសិនបើអ្នកបានមើលឃើញថា អ្នកកំពុងឈរ ហើយរុំដោយស្លឹកល្វា។ នៅពេលដែលព្រះសូរសៀងរបស់ព្រះដ៏ពិតបានមានបន្ទូល មកពួកគេមិនដឹងថានឹងត្រូវធ្វើអ្វីទេ។ វាជាការយល់ច្រឡំ ពួកគេមិនដឹងថានឹងត្រូវធ្វើអ្វីទេ។

81 ភ្លាមនោះលោកណូអេ បានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់។ វាជាការរៀបចំសង្គ្រោះជីវិតរបស់គាត់ ហើយគាត់បានដើរតាមការណែនាំនិងក្រោកឈរ។

82 ប្រសិនបើមនុស្សបានឮព្រះសូរសៀង...ឥឡូវសូមស្តាប់ឲ្យបានពិតប្រាកដ។ កុំចុះចាញ់។ ប្រសិនបើមនុស្សបានឮសំលេងអ្វីមួយ ហើយបើសិនជាវាបានបង្ហាញ ឲ្យឃើញថាជាព្រះសូរសៀងនៃព្រះនៅពេលនោះបន្ទាប់មកការប្រព្រឹត្ត នឹងចេញមកពីមនុស្ស នោះផ្ទៃមេឃផែនដីនឹងរលាយបាត់ប៉ុន្តែព្រះបន្ទូលរបស់ ព្រះមិនរលាយ បាត់ទេ។

83 លោកណូអេបាន ឮព្រះសូរសៀងនៃព្រះ ហើយថ្កោលទោសពិភពលោក។ ហើយពួកគេសើចគាត់ ព្រោះសាររបស់—របស់គាត់ មិនអាចទប់ទល់ជាមួយនឹងសមិទ្ធិផលខាងវិទ្យាសាស្រ្តរបស់ពួកគេនោះទេ ប៉ុន្តែមានភ្លៀងនិងបាន បំផ្លាញពិភពលោកទាំងមូលមែន។ ឃើញទេ?ព្រះសូរសៀងរបស់ទ្រង់ បានក្លាយទៅជាគ្រាប់ពូជត្រូវបានគេដាំនៅទីនោះ។ គ្រប់សម័យកាល និងជារៀង រាល់ថ្ងៃក៏នឹងដូចគ្នាដែរ។

84 សាំយូអែលបានស្រែក ពេលដែលគាត់បានឮព្រះសូរសៀងរបស់ព្រះ ថា លោកជា...ចូរទៅមុខដើម្បីដាក់ទោស ដល់លោកអេលីដែលបានចិញ្ចឹមបីបាច់គាត់។ មនុស្សដែលធ្លាប់ជាឳពុករបស់គាត់ ហើយបានចិញ្ចឹមបី បាច់គាត់។

85 អ្នកដឹកនាំ បងប្អូន ខ្ញុំនឹង? អ្នកដឹកនាំ ជាច្រើនដងលើនិកាយ និងគោលជំនឿរបស់ពួកគេ ប័ណ្ណសម្គាល់របស់ពួកគេ នៅក្នុងហោប៉ៅរបស់ពួកគេ ដែលជាមេនៃនិកាយនេះ ដែលពួកគេបានចិញ្ចឹមបីបាច់ ហើយនាំពួកគេមកវិញ ហើយ ដាក់ពួកគេនៅក្នុងក្រុមជំនុំមួយ ចុះទៅអ្វី ដែលពួកគេបង្រៀន។ អ្នកឃើញទេ? អ្វីដែលជាការគួរឲ្យខ្លាច វានឹងត្រូវបានបង្ហាញសម្រាប់អ្នកបំរើពិតរបស់ព្រះ ដើម្បីស្តាប់ព្រះសូរសៀងរបស់ព្រះនិងត្រូវត្រឡប់មកវិញដោយមានម្តាយដូចគ្នានៅក្នុងក្រុមជំនុំ។ បាននិយាយ ទៀតថា "អ្នកបានទទួលទោសដោយព្រោះតែអ្នកមិនព្រមទទួលព្រះបន្ទូលរបស់ ព្រះ។" តើនោះជាអ្វី!

វាជាការលំបាកណាស់សម្រាប់លោកសាំយូអែល។ ប៉ុន្តែ គាត់ជាហោរា ម្នាក់ គាត់អាចធ្វើវាបាន។ ដោយមិនគិតថាតើវាឈឺចាប់ឬអត់គាត់ត្រូវតែធ្វើវា។

86 លោកម៉ូសេបានឮ ព្រះសូរសៀងរបស់ព្រះ។ លោកបានពេញដោយទេវសាស្ត្រ។ លោកបានដឹង*គ្រប់*ទាំង*សកម្មភាព* ប៉ុន្តែគាត់ បរាជ័យ។ គាត់បានឮសំលេងរបស់ព្រះ លោកម៉ូសេមិនបានដូចកាលពីមុនទេ។

87 ហើយគ្មាននរណាម្នាក់ដូចគ្នាដែរ។ អ្នកអាចនឹងឮ ដោយត្រចៀករបស់អ្នក ព្រះសូរសៀង—ព្រះសូរសៀងដែលកំពុងនិយាយ ប៉ុន្តែ ពេលដែលអ្នកបានស្តាប់ដោយចិត្តរបស់ អ្នកបន្ទាប់មកអ្នកនឹងឮព្រះសូរសៀង ដែល កំពុងនិយាយនោះ។ ឃើញទេ។ អ្នកមិនអាចមើលឃើញដោយភ្នែក របស់អ្នកបានទេ។ អ្នកអាចមើលឃើញដោយចិត្តរបស់អ្នក។ អ្នកមើលឃើញអ្វីមួយ បាននិយាយទៀតថា "ខ្ញុំមិនយល់ទេ" អ្នក មានន័យថា អ្នកមិន យល់ពីវា។ អ្នកមិនស្តាប់ ដោយត្រចៀករបស់អ្នកទេ តែស្តាប់ដោយចិត្តរបស់អ្នកវិញ។ ជាច្រើនដង ត្រចៀករបស់អ្នកបានស្តាប់ ព្រះសូរសៀងដ៏ពិតរបស់ព្រះ ហើយនិយាយ ដូចចាក់ទឹកលើក្បាលទាចឹង។ ប៉ុន្តែពេលអ្នកឮពិតគឺដោយចិត្តរបស់អ្នក។

88 ហើយទេវសាស្ត្រទាំងអស់ ដែលលោកម៉ូសេបានឮគាត់ មិនបានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ទេ។ ប៉ុន្តែនៅថ្ងៃមួយព្រះបានហៅអ្នកគង្វាលអាយុប៉ែត សិបឆ្នាំរូបនេះទៅកន្លែងមួយ និងមានបន្ទូលទៅគាត់ ហើយគាត់ បានយល់។ ទ្រង់បានបង្ហាញថាទ្រង់ជាព្រះជាម្ចាស់។ រឿងដំបូងដែលទ្រង់បានធ្វើចំពោះលោកម៉ូសេគឺទ្រង់មានព្រះបន្ទូលថា ខ្ញុំនឹងបន្ទាបខ្លួនមក "អញនឹងចុះទៅ អញចងចាំពីអ្វីដែលអញបានសន្យា។"

89 ហើយនេះជាអ្វីដែលទ្រង់បានសន្យាសម្រាប់ថ្ងៃចុងក្រោយ។ ទ្រង់លើកមនុស្សចេញពីសាសន៍ដ៏ទៃនិងសម្រេចគ្រប់សេចក្តីសន្យាទាំងអស់។

90 "នេះជាការដែលអញបានសន្យា។" ទ្រង់មានបន្ទូលថា "ម៉ូសេដោះស្បែកជើងរបស់អ្នកចេញ។" ពាក្យម្យ៉ាងទៀត ការគោរព។ "ឥឡូវនេះ ចូរដាក់របស់បររបស់អ្នកចុះ។" ហើយយក—ដំបងស្ងួតបោះទៅ លើដី នោះវានឹង ក្លាយជាពស់ ហើយចាប់វាវិញនោះវានឹងត្រឡប់ទៅជាដំបងវិញ។ ឃើញទេ? គាត់បានដឹងថាទ្រង់ជាព្រះព្រោះព្រះទ្រង់មានបន្ទូលនោះជាព្រះបន្ទូលនៃព្រះ ដែលទ្រង់បានមានបន្ទូល "ចូរបោះដំបងនៅ ក្នុងដៃរបស់អ្នកចុះ។" នោះហើយ ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ កុំព្យាយាមធ្វើដូចនោះ ព្រះមិនបានមានព្រះបន្ទូលមកអ្នកនោះទេ នោះជាព្រះបន្ទូលទៅកាន់ លោកម៉ូសេ។ *នេះ* គឺជាព្រះបន្ទូលរបស់ ព្រះទៅ កាន់

អ្នក! "ចូរបោះដំបងនោះចុះ។" វាក្លាយទៅជាសត្វពស់វិញ។ និយាយថា "ឥឡូវនេះ តើអ្នកខ្លាចវាទេ?ចូរចាប់កន្ទុយវាឡើង" វានឹងត្រលប់ដូចដើមម្តងទៀត។ ព្រះបន្ទូលរបស់ទៅកាន់គាត់។ តើទ្រង់បានធ្វើអ្វី? ព្រះបង្ហាញព្រះបន្ទូលរបស់ទ្រង់។

91 ខ្ញុំបានទទួលការហៅនៅទីនោះប៉ុន្មានខែមុន ប្រហែលមួយឆ្នាំ ឬមួយឆ្នាំជាងហើយ។ ក្មេងស្រីតូចម្នាក់បាននិយាយទូរស័ព្ទជាមួយគ្រូអធិប្បាយបាបទីស្ទនិងគ្រូអធិប្បាយពេនទីកុស្តម្នាក់ទៀត។ នាងបាននិយាយថា "បងប្រុសប្រានហាំ ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំក្លាយជា ហោរា(ស្រ្តី)។"

និយាយ "ល្អណាស់។"

92 និយាយ "អ្នកបានដឹងហើយថាខ្ញុំបានប្រាប់អ្នកថា អ្នក—អ្នកបានបង្កើតកំណត់ត្រាពីព័ន្ធកិច្ចរបស់ខ្ញុំគឺព្រះជាម្ចាស់។"

93 ឥឡូវនេះ ខ្ញុំមិនអាចធ្វើវាបានទេ វាជាការផ្ទុយទៅនឹងព្រះបន្ទូលព្រះ។ ដូច្នេះខ្ញុំបាននិយាយថា "ស្រ្តីនោះជាអ្នកមានកំហុសម្នាក់។ ខ្ញុំមិនដឹងទេ។"

94 ហើយគ្រូអធិប្បាយបាទីស្ទខ្ញុំបានឮគាត់ខ្ញុំបានឮពីអ្នកអធិប្បាយ ពេនទីកុស។ នាងបាននិយាយថា "ល្អ ខ្ញុំមានកិច្ចប្រជុំមួយនៅទីនេះ។" ហើយ បាននិយាយថា"ព្រះអម្ចាស់កំពុងធ្វើការយ៉ាងអស្ចារ្យ។"

95 ខ្ញុំបាននិយាយថា "ខ្ញុំអរគុណសំរាប់ការនេះណាស់"។ នាងបាននិយាយថា... ខ្ញុំនិយាយថា "តើទ្រង់ធ្លាប់ប្រាប់អ្វីខ្លះដល់អ្នក ឬនៅ?"

និយាយ "ចាសខ្ញុំមានកម្មវិធីដ៏អស្ចារ្យត្រូវធ្វើក្នុងដៃ។"

96 ខ្ញុំបាននិយាយថា "អស្ចារ្យ។" ខ្ញុំបាននិយាយថា "ឥឡូវនេះអ្វីដែលជាកម្មវិធីរបស់អ្នក?" ខ្ញុំនិយាយ "តើព្រះអម្ចាស់ ប្រាប់អ្វីដល់អ្នក?"

97 "គាត់បាននិយាយថា 'ចូរទៅទីក្រុង ភូនិច នៃរដ្ឋអារីស្សូណា នៅលើកាលបរិច្ឆេទ*ដាក់លាក់—ដាក់លាក់*មួយហើយបន្ទាប់មក ខ្ញុំនឹងផ្តល់ឲ្យអ្នករកឃើញ អណ្តូងរ៉ែមាសជាតិហូឡង់ដែលបានបាត់បង់ ហើយអ្នកនឹងយកមាសដែល បានរកបាននោះឧបត្ថម្ភដល់បេសកជននៅជុំវិញពិភពលោក។'" នៅពេលដែល យើងទាំងអស់គ្នាដឹងថាការបាត់បង់អណ្តូងរ៉ែជាតិហូឡង់គឺជារឿងព្រេង។ "គាត់បាននិយាយដូច្នេះ។"

98 ខ្ញុំនិយាយថា "ល្អ ខ្ញុំនឹងប្រាប់អ្នកពីរបៀបថាតើជាព្រះឬមិនមែន។" ខ្ញុំបាននិយាយថា "អ្នកមានវត្តមាននៅ ទីនោះ នៅថ្ងៃនោះ។ ហើយប្រសិនបើអ្នករកឃើញអណ្តូងរ៉ែជាតិហូឡ្យង់ដែលបានបាត់បង់នោះ នោះហើយគឺជាព្រះ។ ប្រសិនបើអ្នកមិនបានរកឃើញអណ្តូងរ៉ែជាតិហូឡ្យង់ដែលបានបាត់បង់ទេ អ្នកត្រូវតែផ្លាស់ប្រែ ហើយយកវិញ្ញាណកុហកចេញពីអ្នកទៅ។" នោះជាវិធីស្វែងរក ថាតើមកពីព្រះឬក៏មិនមែន។

99 ព្រះជាម្ចាស់មានព្រះបន្ទូលថា "ម៉ូសេចូរបោះដំបងនេះចុះ នោះវានឹងក្លាយទៅជាសត្វពស់មួយក្បាល។" គាត់បានធ្វើដូច្នោះ។ ទ្រង់មានបន្ទូលថា "ចាប់កន្ទុយវាឡើងវានឹងក្លាយជាដំបងវិញ។" គាត់បានធ្វើដូច្នោះ។

100 នៅពេលដែល ព្រះធ្វើការសន្យានៃព័ន្ធកិច្ចមួយនៅក្នុងថ្ងៃចុងក្រោយនោះ ទ្រង់នឹងបញ្ជាក់វាយ៉ាងច្បាស់ពីវិធីនោះ ទ្រង់មានបន្ទូល ទ្រង់អាចធ្វើបាន។ បន្ទាប់មកអ្នកនឹងដឹងថា អ្នកនឹងទទួលបានព្រះសូរសៀងដ៏ពិត។ អ្នកកំពុងស្តាប់ព្រះសូរសៀងដែលត្រឹមត្រូវព្រោះនោះជាព្រះបន្ទូលដែលទ្រង់បានបញ្ជាក់។ អ្នកឃើញទេ? អូ! ធ្វើយ៉ាងណា...ខ្ញុំសោកស្តាយ ខ្ញុំ...មិនអីទេ។

101 លោកម៉ូសេបានប្រព្រឹត្តផ្ទុយពីនោះ។ មើលរឿងគួរឲ្យ—អស់សំណើចមួយដែលម៉ូសេបានធ្វើ។ ឥឡូវនៅពេលដែលអ្នកតែងតែដើរតាមព្រះសូរសៀងនៃព្រះ អ្នកនិងក្លាយជាមនុស្សឆ្កួតសម្រាប់លោកិយ។ នៅថ្ងៃបន្ទាប់ គេបានឃើញលោកម៉ូសេ និងប្រពន្ធកូនរបស់គាត់ នៅលើភ្លៅរបស់នាង នៅលើរទេះសេះ "កូន" នៅលើភ្លៅរបស់នាងហើយ ពួកគេធ្វើដំណើរទៅភាគខាង ត្បូង។ បុរសចាស់ម្នាក់នេះមានពុកចង្ការដ៏វែង *នេះ* ហើយក្បាលរបស់គាត់ទំពែកឡើងរលោងមានដំបងនៅកាន់នឹងដៃហើយកំពុងនាំលាតូចរបស់គាត់ឆ្ពោះ ទៅស្រុកអេស៊ីបយ៉ាងលំបាកទំរាំទៅដល់បាន។ មានអ្នកខ្លះនិយាយថា "ម៉ូសេតើ អ្នកនឹងទៅកន្លែងណា?"

102 "កំពុងធ្វើដំណើរទៅស្រុកអេស៊ីបដើម្បីធ្វើកិច្ចការល្អមួយ។" កន្លែងដែលគាត់បានបរាជ័យក្នុងនាមជាយុវជនម្នាក់ គាត់បានបរាជ័យ ក្នុងខណៈជាទាហានម្នាក់ ប៉ុន្តែនៅទីនេះគាត់បានទៅ ដើម្បីចាប់ផ្តើម ម្តងទៀត។ ហើយគាត់បានធ្វើវា។ ហេតុអ្វី? គាត់បានឮព្រះសូរសៀងរបស់ព្រះនិងបានឃើញថាវាត្រឹមត្រូវសម្រាប់អ្វីទាំងអស់ក្លាយទៅការល្អរបស់លោក។ លោកបានឃើញវា។

103 លោកប៉ុល ជាពួកមេដឹកនាំលើពួកផារ៉ាស៊ី ពេញដោយទេវសាស្ត្រ ខ្លួនឯង ដូចដែលគាត់អាចធ្វើទៅបាន ប៉ុន្តែនៅថ្ងៃមួយគាត់បានឮ ព្រះសូរសៀងនៃព្រះ។ គាត់បានឃើញបង្គោលភ្លើងមួយ ហើយគាត់បាន ដឹងថា មានអ្វីខុសប្លែកនៅទីនោះ។ វាបានផ្លាស់ប្តូរជីវិតរបស់គាត់។ មិនខ្វល់ថា មានគណៈផារីស៊ី ប៉ុន្មាននាក់ កាម៉ាលាប៉ុន្មាននាក់ឬអ្វីផ្សេងទៀត ដែលសើចឃំដល់ លោកប៉ុលថា "អ្នកធ្វើខុស ហើយ អ្នកធ្វើខុសហើយ" ប៉ុល បានឮព្រះសូរសៀងរបស់ ព្រះជាម្ចាស់ដែលគាត់បានដឹងថានោះជាសេចក្តីពិត។

104 លោកពេត្រុស ជាសាវ័កដែលអាចរក្សាប្រពៃណីទំនៀមទម្លាប់ចាស់ដោយ លោក មិនបរិភោគសាច់។ អត់ទេលោក។ លោកមិនចាំបាច់ធ្វើអ្វី ដែលជា ទម្លាប់ទាំងអស់នោះទេ។ លោកបានរក្សាប្រពៃណីទំនៀមទំលាប់ ចាស់នោះ ថាត្រូវតាមព្រះបន្ទូល។ តើមានអ្វីកើតឡើង? ថ្ងៃមួយគាត់បានឮ ព្រះសូរសៀង របស់ព្រះ "កុំគិតថាវាធម្មតានិងមិនស្អាតឡើយ ពេលដែលអញសម្អាតវាហើយ។" គាត់ជាមនុស្សម្នាក់ដែលបានផ្លាស់ប្រែ។ គាត់បានត្រៀមខ្លួន ជាស្រេចដើម្បីទៅគ្រប់ទីកន្លែង ដែលព្រះអម្ចាស់បានបញ្ជូនគាត់ទៅ។

105 ការបិទ ខ្ញុំអាចនិយាយពាក្យនេះ។ ទីនោះមានបុរសម្នាក់មានពេលមួយ ដែលជាអ្នកជឿ។ លោកបានស្លាប់បួនថ្ងៃហើយ។ គាត់បាននៅក្នុងផ្នូរ មាន ក្លិន ស្អុយរលួយប៉ុន្តែលោកបានឮព្រះសូរសៀងនៃព្រះជាម្ចាស់មាន ព្រះបន្ទូលថា "ឡាសារអើយ ចេញមក!" ហើយប្រសិនបើទ្រង់ បាននាំ បុរសម្នាក់នោះមកបន្ទាប់ពីបានស្លាប់ និងរលួយយកទៅព្រះវិហារ ដោយ គិតថាគាត់នៅមានជីវិត? វាគួរតែប្រាប់ពួកគេ នៅក្នុងសំឡេង ដ៏រញ៉េរញ៉ៃ ទាំងអស់នោះ ដែលយើងបាន និយាយអំពីសាសនា នយោបាយ ហូលីវូដនិងទំនាយមិនពិតទាំងអស់ ដែលបានបាត់បង់។ នៅកណ្តាលចំណោមរបស់ទាំងអស់ព្រះសូរសៀងពិតនៃព្រះនឹងហៅមនុស្សដែលបានស្លាប់នៅក្នុងអំពើបាបនិងអំពើរំលង ដើម្បីបានរស់ជីវិតជាថ្មីម្តងទៀត។ វាគួរតែយកព្រះវិហារដែលបែរចេញ ហើយហៅពួកគេមកឯជីវិតជាថ្មីម្តងទៀត។ ប្រាកដណាស់!

106 សូមចាំថានៅក្នុងការបិទនេះ ខ្ញុំបាននិយាយដូច្នេះ ហើយបន្ទាប់មក ខ្ញុំនឹង បិទ។ ព្រះយេស៊ូវមានព្រះបន្ទូលថា "ពេលវេលានឹងមកដល់ ពេល ដែលមនុស្ស ទាំងអស់នៅក្នុងផ្នូរ បានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់។" ហើយអ្នក

នឹងឮវា។ មិនខ្វល់ថាក្នុងស្ថានភាពណាដែលអ្នកស្ថិតនៅអ្នកនឹងឮវា។ ហើយពួកមនុស្សមួយចំនួនដែលចេញមកពីផ្នូរនឹងមកដល់កន្លែងជំនុំជំរះ។ ពួកគេបានឮព្រះសូរសៀង នោះ តែវាជាការថ្កោលទោស។ ហើយប្រសិនបើអ្នកឮវានៅថ្ងៃនេះ "ថ្ងៃនេះ បន្ទាប់ពីរយៈពេលដ៏យូរដែលឯងបានឮសំលេងរបស់អញ កុំឲ្យចិត្តរបស់ឯងរឹង ទទឹងដូចជាថ្ងៃនៃការជំរុញនោះឡើយ។" ហើយប្រសិនបើ អ្នកជាពួក ពេនទីកុស្ត បង្កើតក្រុមដោយខ្លួនឯងចេញមក នៅក្នុងការបង្រៀន ជាថ្មីម្តងទៀតនៅលោកិយ "ប្រព្រឹត្តខុសបញ្ញត្តិ និងការបដិសេធអំណាចរបស់ព្រះ" មុនដែលអ្នកមានការរស់ឡើងវិញ អ្នកត្រូវបានជំនុំជំរះ ដោយសារតែ ព្រះសូរសៀងនៃព្រះបានមានបន្ទូល ទៅកាន់អ្នកឥឡូវតាមរយៈព្រះបន្ទូលដើម្បីកាត់ទោសអ្នកនៅក្នុងថ្ងៃនោះ។

107 ប្រសិនបើអ្នកគ្រាន់តែជាអ្នកជឿមិនក្តៅមិនត្រជាក់សំលេងរបស់ព្រះនឹងស្រែកក្នុងចិត្តរបស់អ្នកនៅព្រឹកនេះ "អ្នកគឺជាអ្នកជឿដែលមិនក្តៅ ហើយមិនត្រជាក់" អ្នកគួរតែ កែប្រែចិត្តគំនិតរបស់អ្នកឲ្យល្អប្រសើរជាងមុនទៅ!

108 អ្នកជាបុរស ស្ត្រី ក្មេងប្រុស ឬក្មេងស្រីដែលមិនបានរស់នៅក្នុង ព្រះគ្រីស្ទ ព្រះសូរសៀងនៃព្រះមានបន្ទូលទៅអ្នកតាមរយៈព្រះបន្ទូលរបស់ទ្រង់និងបានមានបន្ទូលថា "ឈប់ធ្វើដូច្នោះ" អ្នកអាចធ្វើវាឲ្យល្អប្រសើរជាងនេះបាន។ ដោយសារតែអ្នកនឹងឮវាជាថ្មីម្តងទៀតនៅថ្ងៃណាមួយ ហើយវានឹងជំនុំជំរះ អ្នក។ អ្នកមិនអាចបដិសេធបានទេ ទ្រង់នឹងមានព្រះបន្ទូលទៅអ្នកឥឡូវ។ ចូរចាំថាវាត្រូវបានកត់ត្រាទុក។

109 ហើយអស់អ្នកដែលបានឮព្រះសូរសៀងរបស់ទ្រង់ គេនឹងរស់ឡើង វិញដោយសេចក្តីសុចរិតសម្រាប់សិរីល្អរបស់ព្រះនៅស្ថានបរមសុខ។

110 ដូច្នេះអ្នកនឹងឮ ព្រះសូរសៀងរបស់ព្រះនៅពេលណាមួយ។ ប្រហែលជាខ្យោយនូវអ្វីដែលខ្ញុំនិយាយនៅព្រឹកនេះប៉ះចិត្តរបស់អ្នក តែអ្នកគួរតែ ងាកចេញពីសំឡេងទាំងនោះ ហើយបែរត្រឡប់ទៅឯព្រះវិញ។ ឥឡូវ ចូរចាំថា ពួកគេនឹងកត់ត្រាសំឡេង ដែលខ្ញុំនិយាយទៅក្នុងចិត្តរបស់អ្នក ទុកឯស្ថានសួគ៌។ ហើយនៅពេលដែលព្រះយេស៊ូវ ទ្រង់បានហៅ នោះទាំងមនុស្សដែលនៅក្នុងផ្នូរ ទាំងមនុស្សដែលប្រព្រឹត្តល្អ និងទាំងមនុស្ស ប្រព្រឹត្តអាក្រក់ទាំងអស់ នឹងបានរស់ឡើង។ ហើយបន្ទាប់មកមានព្រះសូរសៀងដូចគ្នាណាស់ នឹងខ្សឹបនៅពីក្រោយ

ខ្ទង់អ្នក។ "នៅក្នុងទីក្រុង ផូនិច នៃរដ្ឋ អារីស្សូណា ជា*ឧម្មតា* នៅព្រឹកថ្ងៃអាទិត្យ នៅពេលដែល អ្នកដឹកនាំបាននិយាយជាច្រើនម៉ោងពីព្រះសូរសៀង ខ្ញុំបាននិយាយ ប្រាប់ទៅអ្នកប្រាប់ទៅ ស្ត្រីដើម្បីឲ្យរុំសក់កុំឲ្យចេញមកក្រៅ ឈប់ស្លៀកពាក់ មិនសមរម្យ បានប្រាប់ទៅបុរសឲ្យឈប់និយាយ ការកុហក ឈប់ជក់បារី បានប្រាប់ដល់គ្រូអធិប្បាយ ឲ្យងាកត្រឡប់មករក ព្រះបន្ទូលរបស់ព្រះវិញ។" អ្នកយល់ពីអ្វីដែលខ្ញុំចង់មានន័យទេ?នោះជាការត្រឹម ត្រូវ។

ហើយនៅតែមានសម្លេងមួយពោលដូច្នោះ "វាអាចជាការត្រឹមត្រូវ។"

111 ប្រសិនបើខ្ញុំបានដូចជា លោកនីកូដេម ខ្ញុំនឹងនៅតែព្យាយាមដើម្បីទៅដល់ទីនោះ។ ខ្ញុំនឹងមករកទ្រង់ហើយចេញទៅទីនោះនៅវាលរហោស្ថានឬកន្លែងណាមួយហើយនិយាយថា "ព្រះអម្ចាស់ដ៏ជាព្រះ ទូលបង្គំនៅទីនេះ សូមទ្រង់ផ្លាស់ប្រែ ខ្ញុំឥឡូវនេះ។ សូនខ្ញុំតាមព្រះហឫទ័យទ្រង់។" សូមឲ្យខ្ញុំបានត្រឡប់ មករកព្រះបន្ទូលវិញ។ កន្លែងណាដែលទ្រង់បាន ទតឃើញ សូមទ្រង់បានទុកព្រះបន្ទូលនៅទីនោះដោយសារតែខ្សែចំណងមួយយ៉ាងខ្លាំងបំផុត វាបានក្លាយទៅ ជាទាបបំផុតវិញ។ ហើយនៅគ្រប់ទីកន្លែងនៅក្នុងជីវិតរបស់អ្នកដែល អ្នកបានចាកចេញពីបញ្ញរបស់ព្រះជាម្ចាស់បម្រើតែប្រពៃណី ទីនោះហើយកន្លែងនឹង បំផ្លាញច្រវ៉ាក់នោះដោយមិនខ្វល់ថាវារឹងមាំប៉ុនណានោះទេ។ តោងជាប់ព្រះហស្ថមិនផ្លាស់ប្រែ របស់ព្រះ។

112 សូមឲ្យយើងអធិស្ឋាន។ ថ្ងៃនេះ បន្ទាប់ពីរយៈពេលដ៏យូរ ព្រះអម្ចាស់អើយ ទ្រង់មានបន្ទូលថា ទ្រង់អាចមានបន្ទូល ទ្រង់នឹងសរសេរបញ្ញត្តិ របស់ទ្រង់ នៅលើតារាងនៃចិត្តរបស់មនុស្ស។ ខ្ញុំមិនដឹងថានឹងជួបអ្វី នៅចំពោះមុខខ្ញុំ។ រឿងតែមួយគត់ដែលខ្ញុំបានដឹងគឺខ្ញុំគួរតែយកព្រះបន្ទូល របស់ទ្រង់ដើម្បីផ្សាយដំណឹងល្អដល់អ្នកដទៃ ពិតប្រាកដណាស់ ខ្ញុំនឹងទៅ ដល់កន្លែងណាមួយដែលមានការពិបាកបន្តិច។ ខ្ញុំអធិស្ឋានទៅព្រះអម្ចាស់ ទ្រង់នឹងមានព្រះបន្ទូល ទៅមនុស្សគ្រប់វ័យ វ័យក្មេង វ័យកណ្តាល វ័យចំណាស់ គ្រប់អ្នកដែលអាច។ សូមព្រះអម្ចាស់មានព្រះបន្ទូល ដល់ចិត្ត របស់ខ្ញុំផង។ មានបន្ទូលទៅកាន់ ដួងចិត្តរបស់មេដឹកនាំទាំងនោះផង។ និងទៅកាន់ចិត្តរបស់ក្រុមជំនុំផង។

113 យើងអធិស្ឋានព្រះវរបិតាអើយ ថ្ងៃនេះយើងនឹង ឮព្រះសូរសៀងរបស់ទ្រង់។ ហើយយើងដឹងថា ដូចគ្នានឹងថ្ងៃរបស់សាំយូអែលដែរ ដែលបានបើកនូវនិមិត្តដ៏

កម្រហើយបានពញ្ញាក់ដល់មនុស្សជាច្រើន។ ដូច្នេះវា ដូចថ្ងៃនេះដែរ។ យើងមាន ក្ដីសុបិន្តនិងអ្នកសុបិន្តមានអ្នកអធិប្បាយនិងអ្នកបកប្រែ ប៉ុន្តែការបើកនិម្មិត ចេញមកជាមួយនឹងព្រះបន្ទូលនៃព្រះអម្ចាស់ ជាអ្នកកែតម្រូវ...យើងអធិស្ឋានដល់ ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ សំឡេង ដែលគេបានស្រែកនៅវាលរហោស្ថាន នោះថា "ចូររៀបចំផ្លូវ សម្រាប់ ព្រះអម្ចាស់" យើងជឿថាព្រះវិញ្ញាណបរិសុទ្ធ នឹង ផ្ដល់នូវព្រះសូរសៀងនោះ នៅថ្ងៃនេះម្ដងទៀតថា "ចូររៀបចំផ្លូវសម្រាប់ការយាងមក របស់ព្រះអម្ចាស់!" ហើយតើប្លែកយ៉ាងណា មូលហេតុគឺដោយសារមានសំលេង ផ្សេងទៀត ជាច្រើនឲ្យយើងស្ពឹកហើយយកយើងចេញពីព្រះ ប៉ុន្តែវាជាការសន្ដោស ប្រណីដល់អស់អ្នកដែល បានស្ដាប់ឮវា។ ខ្ញុំអធិស្ឋានសូមឲ្យព្រះវិញ្ញាណបរិសុទ្ធ ធ្វើការនៅក្នុង ដួងចិត្តរបស់ យើងទាំងអស់គ្នាឥឡូវនេះ។

114 ហើយនៅខណៈពេលដែលយើងឱនក្បាលរបស់យើង ខ្ញុំជឿជាក់លើ ចិត្ត របស់យើងក៏បានបន្ទាបចុះដែរ ប្រសិនបើអ្នកដឹងថានៅកន្លែងណាមួយ ដែលអ្នក មិនទាន់បានស្ដាប់បង្គាប់ក្នុងជីវិតរបស់អ្នក បទគម្ពីរមួយចំនួន ដែលអ្នកមិនបាន ដឹង នោះជាការបង្រៀននៃព្រះគម្ពីរ ដែលតែងតែធ្វើ ការជាមួយ ព្រោះសំឡេង នៃពួកហូលីវូដ បានធ្វើឲ្យអ្នកខុសប្លែកពីមុន។ កន្លែងមួយចំនួនដែលមេដឹកនាំ បានដឹងថា នៅក្នុងព្រះគម្ពីរជាសេចក្ដីពិត ប៉ុន្តែអ្នកដឹងពីក្រុមជំនុំនោះតែ អ្នក នៅតែ ទទួលការបង្រៀនដូច្នោះហើយ អ្នកដឹងច្បាស់ថាវាជាសេចក្ដីពិត។ សម្រាប់ មនុស្ស ដែលបានប្រព្រឹត្តខុស រស់ក្នុងជីវិតដែលមានកំហុស។ សម្រាប់ ឪពុកម្ដាយ ដែល មិនបានប្រដៅកូនចៅនឹងមិនចិញ្ចឹមពួកគេ។ អ្នកប្រហែលជា កំពុងព្យាយាម ឲ្យបានល្អបំផុតដើម្បីឲ្យពួកគេរស់នៅក្នុងលោកិយមិនថាយ៉ាងណានោះទេ ប៉ុន្តែ អ្នកបានធ្វើជាគំរូ សម្រាប់ពួកគេរួចទៅហើយ។ ហើយប្រសិនបើអ្នកមិនបាន ធ្វើ ដូច្នោះទេព្រះសូរសៀងរបស់ព្រះ និយាយទៅកាន់អ្នក ឥឡូវ "កុំធ្វើដូចនោះ។"

115 ហើយឥឡូវនេះជាមួយនឹងក្បាលឱនចុះ ហើយបិទភ្នែកទាំងអស់គ្នា ព្រះ នៃស្ថានសួគ៌បានទតមើលក្នុងដួងចិត្តរបស់មនុស្សម្នាក់ៗ ដែលកំពុងតែឃ្លាន និង រកឲ្យឃើញពីចំនុចដែលពួកគេខុស។ ហើយជាមួយនឹងដៃប្រណំ ដល់ព្រះ ហើយនិយាយថា "ព្រះអម្ចាស់ទូលបង្គំពិតជាត្រូវការព្រះសូរសៀងទ្រង់ដើម្បីដក អស់ទាំងការសង្ស័យហើយនឹងអ្វីៗដែលមិនដូចទ្រង់ចេញពីទូលបង្គំ សូមទ្រង់

កែច្នៃទូលបង្គំតាមបំណង ព្រះហឫទ័យរបស់ទ្រង់ចុះ” សូមលើកដៃរបស់អ្នកឡើង។ ខណៈពេលអ្នក...សូមព្រះអម្ចាស់ប្រទានពរ។ សូមព្រះប្រទានពរ។

116 បន្ទាប់មកព្រះគម្ពីរបានចែងហើយព្រះយេស៊ូវមានបន្ទូលថា ថ្វីបើមានសំឡេងផ្សេងជាច្រើន “ប៉ុន្តែប្រសិនបើមនុស្សឮសំលេងខ្ញុំ។” ដើរជាប់ជាមួយទ្រង់អ្នកនឹងសម្រេចបំណងប្រាថ្នារបស់អ្នក។

117 ព្រះអម្ចាស់អើយពេលវេលាគឺ កំពុងរត់ចេញពីទូលបង្គំ។ ប៉ុន្តែព្រះគម្ពីរបានចែងថា “ដរាបណាអ្នកជឿ អ្នកត្រូវទទួលពិធីជ្រមុជទឹក។” ខ្ញុំបានអធិស្ឋានដល់ព្រះវរបិតាអស់អ្នកដែលលើកដៃសារភាពការពិត ព្រះបន្ទូល របស់ព្រះជាម្ចាស់ដែលពួកគេបានអាន និងបានដឹងពីកំហុសរបស់ពួកគេ។ ខ្ញុំមិនបានមើលទៅពួកគេទេ។ វាមិនមែនជាការសម្រាប់ទូលបង្គំមើលនោះទេតែសម្រាប់ទ្រង់ទតមើលព្រះអម្ចាស់អើយ។ ទ្រង់ដឹងថាការជម្រុញនិងគោលបំណងនៅពីក្រោយដៃដែលបានលើកឡើង។ អនុញ្ញាតឲ្យពួកគេចាប់ពីម៉ោងនេះ គោលបំណងនៅក្នុងចិត្តរបស់គេ “ចាប់ពីពេលនេះទូលបង្គំនឹងយកព្រះបន្ទូលនិង ព្រះសូរសៀងរបស់ទ្រង់តាមជាប់ ជានិច្ចមិនថាតំលៃណានោះទេ។” ហើយសេចក្តីក្លាហាននៅ ក្នុងចិត្តរបស់ពួក គេខណៈដែលពួកគេនឹងច្រៀង ចម្រៀងនៃកំណាព្យនេះ “តើព្រះយេស៊ូវត្រូវតែ លីឈើឆ្កាងតែម្នាក់ឯងហើយ ពិភពលោកទាំងមូលបាន សង្គ្រោះ? គ្មានទេឈើ ឆ្កាងគឺសម្រាប់អ្នករាល់គ្នាហើយសម្រាប់ខ្ញុំ។ ហើយឈើឆ្កាង បានញែកពីការកើត រហូតដល់ស្លាប់ហើយបានកំណត់ឲ្យខ្ញុំមានសេរីភាពឡើង វិញ។” បន្ទាប់មកនៅ ពេលដែល ព្រះសូរសៀង របស់ព្រះបានមានបន្ទូលមកថា “ខ្ញុំនឹងស្វែងរកសេចក្តីសុចរិតរបស់ទ្រង់ដើម្បីខ្ញុំបានអនុវត្តតាមព្រះសូរសៀងនៃ ព្រះបន្ទូលរបស់ទ្រង់។” ខ្ញុំថ្វាយទៅទ្រង់ឥឡូវនេះនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ។

118 ឥឡូវខណៈដែលយើងបានឱនក្បាលរបស់យើង អ្នកបានសារភាពទោសកំហុសរបស់អ្នក ហើយបានសន្យារជាមួយទ្រង់។ ខ្ញុំបានភ្ញាក់ផ្អើល យ៉ាងខ្លាំង នៅពេលក្មេងប្រុសតូចម្នាក់បានអង្គុយនៅទីនេះ ហើយក្បាលរបស់គាត់ងាកចុះងាកឡើងៗ។ ហើយនៅនោះគឺជាសំលេងសម្រាប់ក្រុមជំនុំ។ “អញជាព្រះអម្ចាស់ ជាអ្នកដែលប្រោសជំងឺទាំងអស់របស់អ្នកឲ្យបានជា។” នោះជាព្រះសំឡេង មួយនៅក្នុងព្រះវិហារ។ ហើយអ្នកទាំងអស់គ្នាដែលត្រូវការការព្យាបាលហើយជីវិតអ្នក កំពុងរស់នៅក្នុងព្រះបន្ទូលព្រះ ហើយអ្នកដឹងអ្វីជាការត្រឹមត្រូវ

ហើយអ្នកត្រូវការការព្យាបាល ខ្ញុំឆ្ងល់ណាស់ ប្រសិនបើ គ្រាន់តែលើកដៃរបស់អ្នកសោះ។ លើកដៃអ្នកឡើងហើយថា "ព្រះជាម្ចាស់ខ្ញុំត្រូវការ ការការព្យាបាលមួយ។"ល្អ។

119 ឥឡូវសូមរក្សាព្រះសូរសៀងនៅក្នុងចិត្តរបស់អ្នក "អញជាព្រះអម្ចាស់ ដែលប្រោសជំងឺទាំងអស់របស់ឯង។" សូមចាំថានៅពេលដែលព្រះបន្ទូលរបស់ព្រះបានមានបន្ទូលវាត្រូវបានសម្រេច។ ព្រះយេស៊ូវ មានព្រះបន្ទូលនៅម៉ាកុស ជំពូក ១១ ខ ២២ "ប្រសិនបើអ្នកនិយាយទៅកាន់ភ្នំ 'អោយរើចេញ' ដោយគ្មានការ សង្ស័យនៅក្នុងចិត្តរបស់អ្នកប៉ុន្តែអ្នកត្រូវជឿថាអ្វីដែលអ្នកបាននិយាយវា នឹងកើតឡើងអ្នកអាចសម្រេចនូវអ្វីដែលអ្នកបាននិយាយ។"

120 ឥឡូវនេះគ្រប់គ្នានៅក្នុងផ្លូវរៀងៗខ្លួន ចូរឱនក្បាលរបស់អ្នកសារភាពកំហុសរបស់អ្នកថា"ព្រះអម្ចាស់អើយទូលបង្គំជឿលើព្រះបន្ទូលរបស់ទ្រង់។ ទូលបង្គំបានឮព្រះសូរសៀងរបស់ទ្រង់ប្រាប់ទូលបង្គំថា ទ្រង់ដូចគ្នានឹងកាលពី ម្សិលមិញថ្ងៃនេះនិងជារៀងរហូតដែរ។" ទូលបង្គំនឹងដើរទៅមុខហើយដាក់ដៃលើក្មេងនេះព្រោះគាត់នៅក្មេងណាស់ក្នុងការដឹង ក្មេងតូចដ៏មានតម្លៃនេះរាងកាយនិងអាយុប្រហាក់ប្រ ហែលទៅនឹងកូនតូចរបស់ទូលបង្គំយ៉ូសែបដែរ។ ហើយខ្ញុំចង់ឲ្យអ្នកទាំងអស់គ្នា អធិស្ឋាននិងទូលអង្វរថា "ព្រះអម្ចាស់ខ្ញុំឮព្រះសូរសៀងរបស់ទ្រង់។ ខ្ញុំជឿជាក់។"

121 ព្រះវរបិតានៃស្ថានសួគ៌ យើងកំពុងនាំពួកគេនេះមកចំពោះទ្រង់ ដើម្បីទទួលការព្យាបាលនៃរាងកាយរបស់ពួកគេពីទ្រង់។ ហើយព្រះអម្ចាស់នៅទីនេះមានក្មេងតូចក្រីក្រម្នាក់គាត់មានការយកចិត្តទុកដាក់ស្តាប់ ព្រះបន្ទូលពីខ្ញុំណាស់តាំងពីដំបូងម្លេះ គាត់អង្គុយនៅទីនោះ ជាមួយក្មេងៗឯទៀតនោះ។ តាមរយៈ វេជ្ជសាស្រ្តពេទ្យគេគ្មានសង្ឃឹមថា អាចព្យាបាលជម្ងឺ សម្រាប់ក្មេងតូចនេះបានទេ។ មានតែព្រះសូរសៀងនៃព្រះទេដែលព្យាបាលអ្វីគ្រប់យ៉ាងបាន។ ហើយក្រុមជំនុំនេះបានចូលមកបម្រើការងារជាមួយគ្នាគ្រប់ទាំង បទបញ្ជាដែលខ្ញុំបានដឹងពីរបៀបដែលត្រូវធ្វើ កិច្ចការផ្សេងទៀតជារបស់ទ្រង់ព្រះវរបិតា។ ទូលបង្គំកំពុងដើរទៅហើយដាក់ ដៃលើកុមារតូចនោះ។

122 ព្រះវរបិតា ជាព្រះនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទទូលបង្គំសូមថ្កោល ទោសការនេះ។ ព្រះជាម្ចាស់ សូមឲ្យអំណាចទ្រង់បានព្យាបាល...សូមឲ្យទ្រង់បាន ផ្លាស់

ប្ដូរអ្នកនោះនៅក្នុងរយៈពេលប្រាំនាទីក្រោយ។ សូមឲ្យពួកគេទាំងអស់បាន មក ដើម្បីថ្វាយសិរីរុងរឿងដល់ទ្រង់។

123 ព្រះវរបិតានៃស្ថានសួគ៌ទ្រង់ប្រទានការសន្យា។ នោះហើយជាអ្វីដែលទូលបង្គំដឹងទ្រង់បានផ្ដល់ការសន្យានោះមក។ វាបានសម្រេចដូច ដែលទ្រង់បានមានបន្ទូលថា "ប្រសិនបើជាអ្នក*និយាយ*ដូចនេះ" ហើយ អញនិយាយ ទៅគ្រប់អារក្ស នៃជំងឺឬទំនាស់ ដែលបានចងពួកគេនេះ ដែលចងមនុស្សទាំងនេះគ្រប់ទាំងវិញ្ញាណនៃការមិនជឿអញបញ្ជា "ចូរថយចេញពីប្រជាជនទាំងនេះ ក្នុងព្រះនាមនៃ ព្រះយេស៊ូវគ្រីស្ទ!" ឥឡូវយើងដឹងថាវាត្រូវបានសរសេរហើយ ហើយត្រូវបានគេនិយាយសូមឲ្យបានសម្រេចចុះដោយកិត្តិយស និងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ ហើយដោយសូមនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ។

124 ឥឡូវនេះ សម្រាប់អ្នកដែលអាចជឿ សូមជឿ មិនខ្វល់ថាបញ្ហាអ្វីនឹងកើតឡើង មិនត្រូវធ្វើជាគ្រាប់ពូជដែលធ្លាក់នៅទីនោះទេ។ នោះជាអ្វីមួយតូច នៅក្នុងចិត្តអ្នករាល់គ្នា។ ឪពុកម្ដាយរបស់ក្មេងនេះមិនខ្វល់ថា កុមារស្ថិតក្នុងស្ថានភាពណានោះទេ អ្នកជឿថាគ្រាប់ពូជរបស់ព្រះបានធ្លាក់ចុះទៅក្នុងចិត្តរបស់អ្នក ក្មេងប្រុសនោះនឹងបានជាសះ ស្បើយ? អ្នកផ្សេងទៀតត្រូវអធិស្ឋានអោយគ្នាទៅវិញទៅមក តើអ្នកជឿថាគ្រាប់ពូជរបស់ព្រះបានធ្លាក់ចុះទៅក្នុងចិត្តរបស់អ្នកទេ "ជម្ងឺរបស់ខ្ញុំនឹងត្រូវបានបញ្ចប់ឬអត់"? បន្ទាប់មក ការអធិស្ឋាននៃសេចក្ដីជំនឿ ត្រូវបានអធិស្ឋានសម្រាប់អ្នក ចូរបន្ទាបខ្លួនចុះ។ បើមារសាតាំងព្យាយាម នាំអ្នកទៅវិញ "ចូរនៅក្នុងព្រះវិហារ របស់អេស្ប៉ាញ នោះរាល់ព្រឹកថ្ងៃអាទិត្យសូមការអធិស្ឋាននៃសេចក្ដីជំនឿដើម្បីអធិស្ឋានសម្រាប់ខ្ញុំ។ ហើយព្រះបានសន្យា!" ការអធិស្ឋាននៃសេចក្ដីជំនឿ នឹងសង្គ្រោះអ្នកពីជម្ងឺ ហើយព្រះទ្រង់នឹងលើកពួកគេឡើង។ វានឹងកើតមាន។ តើអ្នកជឿទេវា? ហើយ និយាយថា"អាម៉ែន" [គ្រូគង្វាលបាននិយាយថា"អាម៉ែន។"—Ed។] សូមព្រះប្រ ទានពរអ្នក។ ឥឡូវនេះខ្ញុំនឹងប្រគល់កម្មវិធីនេះទៅបងប្រុសរ៉ូសវិញខ្ញុំគិតថាខ្ញុំនឹង ឈប់ត្រឹមនេះ បងប្រុស ថ្វែល រ៉ូស។

# ព្រះសូរសៀងរបស់ព្រះនៅថ្ងៃចុងក្រោយ KHM63-0120M

(The Voice Of God In This Last Days)

សារដែលធ្វើឡើងដោយ William Marrion Branham នេះ ត្រូវបានចែកចាយនៅព្រឹក ថ្ងៃអាទិត្យ ថ្ងៃទី ២០ មករា ១៩៦៣ នៅ Apostolic Church នៃទីក្រុង Phoenix, Arizona, U.S.A.។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀង ផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថត ចម្លង និង បោះពុម្ព ដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ វ៉យ អូហ្វ ហ្គដ់ រីខដ ឌីង។

KHMER

©2018 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវេបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG